**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de droit et des sciences Économoiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាខ្ចីបរិភោគ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ហុង សិរីបរិញ្ញា**
លោកស្រី **សយ សុគន្ធរី**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក ខុឌ្ឍី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហុង សិរីបរិញ្ញា** និង នាងខ្ញុំឈ្មោះ **សយ សុគន្ធរី** ជានិស្សិតបរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ក្រុម **L4C2** និង **L4C3** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយវាចាចិត្តគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក អ្នកម្ដាយ ជាទីគោរពដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ អប់រំទូន្មាន ប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ដើម្បីឲ្យកូនៗក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អក្នុងសង្គម។ ម្យ៉ាងវិញទៀត អ្នកមានគុណថែមទាំងផ្គត់ផ្គង់ និងលះបង់គ្រប់បែបយ៉ាង ទាំងកំលាំងកាយ ទាំងកំលាំងចិត្ត ដើម្បីឲ្យកូនបានសិក្សាតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់បរិញ្ញបត្រនេះ។ខ្ញុំទាំងពីរសូមក្រាបប្រតិបត្តិនិងសូមសម្ដែងនូវកតញ្ញូតាធម៌ ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណទាំងពីរ។

ឯកឧត្ដមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ និងមន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានចំណាយញើសឈាម និងពេលវេលាដ៏មានតំលៃក្នុងការបង្ហាត់បង្រៀននិងផ្ដល់នូវចំណេះដឹងក៏ដូចជាយោបល់ល្អៗដល់រូបខ្ញុំទាំងពីរ។

លោកសាស្ត្រាចារ្យ **ញឹក ឧុធ្ធី** ដែលបានផ្ដល់នូវចំណេះដឹង គំនិត មតិយោបល់និងវិធីសាស្ត្រល្អៗក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះប្រកបដោយជោគជ័យ។

ជាចុងក្រោយខ្ញុំទាំងពីរនាក់សូមបួងសួងដល់វត្ថុស័ក្ដសិទ្ធតាមថែរក្សាការពារ លោកឪពុក អ្នកម្ដាយ និងអ្នកមានគុណទាំងអស់ សូមឲ្យជួបពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

មនុស្សយើងម្នាក់ៗរស់នៅក្នុងសង្គមត្រូវតែមានការប្រាស្រ័យទាក់ទងគ្នាជាចាំបាច់។ យ៉ាងណាមិញដើម្បីឲ្យ ការរស់នៅប្រកបដោយសេចក្តីសុខសាន្តលុះត្រាតែសង្គមនោះបានបញ្ញត្តិនូវច្បាប់ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តិផ្សេងៗមកពង្រឹងសន្តិសុខនិងស្ថេរភាពក្នុងសង្គមជាពិសេសគឺជួយការពារនិងកំណត់នូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូបចៀសវាងការរំលោភបំពានផ្សេងៗដោយប្រការណាមួយ។

យើងដឹងហើយថាកិច្ចសន្យាគឺបានផ្សារភ្ជាប់យ៉ាងសំខាន់ក្នុងជីវភាពរស់នៅរបស់ប្រជាជន។ នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវមាត្រាជាច្រើនដែលពាក់ព័ន្ធជាមួយនឹងកិច្ចសន្យាដែលមានដូចជា៖ កិច្ចសន្យាលក់ទិញ កិច្ចសន្យាខ្ចីប្រើ កិច្ចសន្យាក្រុមហ៊ុន កិច្ចសន្យាការងារជាដើម។ ជាក់ស្តែងកិច្ចសន្យាខ្ចីបរិភោគគឺជាប្រតិបត្តិការមួយយ៉ាងសំខាន់នៅក្នុងសង្គមផងដែរមិនថាសង្គមណាជាសង្គមណាទេពីព្រោះវាមានទំនាក់ទំនងជាមួយប្រជាពលរដ្ឋទូទៅជាប្រចាំ។ មួយវិញទៀតប្រតិបត្តិការនេះមិនត្រឹមតែប្រើក្នុងជំនួញជួញដូរទេ កិច្ចសន្យានេះក៏ប្រើសំរាប់តម្រូវការរបស់ប្រជាជនដូចជាការខ្ចីជាវត្ថុ ស្បៀងអាហារ ប្រាក់កាក់ផ្សេងៗដើម្បីធ្វើការដោះដូរ និងខ្ចីទៅវិញទៅមកដែលជាមធ្យោបាយក្នុងការទូទាត់ទំនិញប្រចាំថ្ងៃសំរាប់ជាការរស់នៅ។

អាស្រ័យហេតុនេះហើយទើបជំរុញឲ្យយើងខ្ញុំទាំងពីរនាក់សំរេចចិត្តលើកយកប្រធានបទកិច្ចសន្យាខ្ចីបរិភោគមកធ្វើជាប្រធានបទសំរាប់ធ្វើការសរសេរសារណាបញ្ចប់ការសិក្សា។សារណានេះបែងចែកជាបីជំពូកធំៗនៅក្នុងនោះមានការបកស្រាយលម្អិតអំពីបទបញ្ញត្តិនានា គោលការណ៍ទូទៅនិងទស្សនៈផ្សេងៗនៃកិច្ចសន្យាខ្ចីបរិភោគ ដូចជា ការបង្កើតកិច្ចសន្យា វិការៈនិងសុពលភាពនៃកិច្ចសន្យា ជនដែលមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ កម្មវត្ថុនៃកិច្ចសន្យា អត្រាការប្រាក់ ករណីយកិច្ចរបស់អ្នកឲ្យខ្ចីនិងអ្នកខ្ចីជាដើមដែលសុទ្ធតែមានការពាក់ព័ន្ធយ៉ាងស្អិតរមួតក្នុងប្រធានបទមួយនេះ។

យើងខ្ញុំមានសេចក្តីសង្ឃឹមទុកនៅក្នុងចិត្តថាការស្រាវជ្រាវមួយនេះនឹងបានចូលរួមផ្តល់នូវអត្ថប្រយោជន៍ សម្រាប់ការស្រាវជ្រាវពីសំណាក់សិស្ស និស្សិត ដែលមានចំណាប់អារម្មណ៍លើប្រធានបទទាក់ទងនឹងកិច្ចសន្យាខ្ចី បរិភោគ។ ម្យ៉ាងវិញទៀតយើងខ្ញុំក៏សូមធ្វើការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលកើតមានដោយអចេតនាក្នុងការរៀបចំសំណេរនិងអត្ថន័យជាដើម។

ជាចុងបញ្ចប់យើងខ្ញុំសូមប្រសិទ្ធពរជ័យដល់អ្នកអានទាំងអស់អោយទទួលបាននូវពុទ្ធពរទាំងបួនប្រការក្នុងជីវិត។ យើងខ្ញុំទាំងពីររីករាយចំពោះការរិះគន់ដើម្បីស្ថាបនាគ្រប់ពេលវេលា។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ......................................................................................... ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ......................................................................... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ....................................................................... ១

៣. គោលបំណងនៃការស្រាវជ្រាវ ......................................................................... ២

៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ................................................................. ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ......................................................................... ២

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ..................................................................... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......................................................................... ៣

**ជំពូកទី១**

**ប្រវត្តិនិងសញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ**

១. ប្រវត្តិនៃកិច្ចសន្យាខ្ចីបរិភោគ ......................................................................... ៤

២.សញ្ញាណនៃកិច្ចសន្យាខ្ចីបរិភោគ ...................................................................... ៦

២.១.១ និយមន័យតាមអក្សរសាស្ត្រខ្មែរ .................................................................. ៦

២.១.២ និយមន័យតាមនីតិសាស្ត្រ ........................................................................ ៧

២.១.៣ កម្មវត្ថុ .................................................................................................. ៧

ក. ប្រាក់ .......................................................................................................... ៧

ខ. ស្បៀងអាហារ ............................................................................................... ៨

គ. វត្ថុជំនួសផ្សេង .............................................................................................. ៨

៣. ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ ...................................................................... ៨

៣.១ កិច្ចសន្យាខ្ចីបរិភោគមានការប្រាក់ .................................................................. ៨

៣.២ កិច្ចសន្យាខ្ចីបរិភោគគ្មានការប្រាក់ .................................................................. ៩

**ជំពូកទី២**

**លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ**

១. ការបង្កើតកិច្ចសន្យា ...................................................................................... ១០

១.១ការបង្កើតកិច្ចសន្យាដោយសំណើនិងស្វីការ ...... ១០
១.១.១ គោលការណ៍...... ១០
១.១.២ ករណីលើកលែង ...... ១០
១.២ និយមន័យសំណើនិងស្វីការ ...... ១០
១.២.១ និយមន័យសំណើ...... ១០
១.២.២ ភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ ...... ១១
១.២.៣ ពេលដែលបង្កើតអានុភាពនៃសំណើ...... ១១
១.២.៤ និយមន័យស្វីការ...... ១២
១.២.៥ សំណើខ្វែង ...... ១២
១.២.៦ ពេលដែលបង្កើតអានុភាពនៃស្វីការ ...... ១៣
២. វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា ...... ១៣
២.១ ការពិចារណាជាមូលដ្ឋាន ...... ១៣
២.២ ការបង្ហាញឆន្ទៈដោយមានវិការៈ...... ១៣
២.៣ ការភាន់ច្រឡំ ...... ១៤
២.៣.១ និយមន័យ...... ១៤
២.៣.២ ប្រភេទនៃការភាន់ច្រឡំ ...... ១៤
ក. ការភាន់ច្រឡំក្នុងកិច្ចសន្យា ...... ១៤
ខ. ការភាន់ច្រឡំអង្គហេតុសំខាន់ចំពោះភាគីម្ខាង ...... ១៥
គ. ការភាន់ច្រឡំរួម...... ១៥
២.៤ ការឆបោក ...... ១៦
២.៥ ព័ត៌មានមិនពិត...... ១៦
២.៦ ការរំលោភបំពានលើស្ថានភាព ...... ១៧
២.៧ការគំរាមគំហែង...... ១៧
២.៨ ការកេងយកចំណេញហួសហេតុ...... ១៨
២.៩ ឋបនីយផ្លូវចិត្ត ...... ១៨
២.១០ ការបង្ហាញឆន្ទៈមិនពិត...... ១៩
៣.សមត្ថភាព...... ១៩

៣.១ នីតិជន.................................................................................................................. ១៩
៣.២ អនីតិជន..................................................................................................................២០
៣.៣ អនីតិជនដែលទទួលបានអត្តាធីនភាព ...........................................................................២០
៣.៤ ជននៅក្រោមអាណាព្យាបាលទូទៅ .............................................................................២១
៣.៥ ជននៅក្រោមហិតូបត្ថម្ភ...............................................................................................២២
៤.កម្មវត្ថុ........................................................................................................................... ២៣
៤.១ កម្មវត្ថុស្របច្បាប់ ..................................................................................................... ២៣
៤.២ កម្មវត្ថុអាចធ្វើកើត...................................................................................................... ២៣
៤.៣ កម្មវត្ថុជាក់លាក់.........................................................................................................២៤

## ជំពូកទី៣
## ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ

១. និយមន័យ ...................................................................................................................២៦
២. ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ.........................................................................................២៦
៣. ការរំលាយកិច្ចសន្យា ......................................................................................................២៧
៤. ការខ្ចីបរិភោគដោយគ្មានការប្រាក់ ...................................................................................២៨
៥. ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ....................................................................................២៨
៦. អត្រាការប្រាក់................................................................................................................២៩
៦.១ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់..........................................................................២៩
៦.២ អត្រាការប្រាក់ក្នុងកិច្ចសន្យា..........................................................................................២៩
៦.៣ ការកម្រិតការប្រាក់.......................................................................................................៣០
៦.៤ ពេលវេលានៃការបង់ការប្រាក់និងការប្រាក់សមាសដែលកំណត់ដោយច្បាប់ .............................៣១
៦.៤.១ ពេលវេលានៃការបង់ការប្រាក់ .....................................................................................៣១
៦.៤.២ ការប្រាក់សមាសដែលកំណត់ដោយច្បាប់.......................................................................៣១
៧. អនុវត្តកិច្ចសន្យាខ្ចីបរិភោគ ............................................................................................ ៣២
៧.១ កាតព្វកិច្ចអ្នកឱ្យខ្ចី ..................................................................................................... ៣២
៧.១.១ ករណីឲ្យខ្ចីវត្ថុដែលជាកម្មវត្ថុ....................................................................................... ៣២

៧.១.២ ការទទួលខុសត្រូវក្នុងការធានារបស់អ្នកខ្ចី.................................................................. ៣២
ក- ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចីក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ ...................... ៣២
ខ- ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឲ្យខ្ចីនូវវត្ថុដែលមានវិការៈ .................................. ៣២
៧.២ ករណីយកិច្ចរបស់អ្នកខ្ចី ........................................................................................ ៣៣
៧.២.១ករណីយកិច្ចត្រូវសង ...........................................................................................៣៤
ក- ពេលវេលានៃការសង ...........................................................................................៣៤
ខ- ទីកន្លែងនៃការសង................................................................................................៣៥
គ- ករណីដែលអ្នកខ្ចីមិនអាចសងវត្ថុបាន ..........................................................................៣៥
៧.២.២ កាតព្វកិច្ចបង់ការប្រាក់ .........................................................................................៣៥
៨. បញ្ហាទូទៅដែលកើតមានក្នុងកិច្ចសន្យាខ្ចីបរិភោគ......................................................................៣៦
**សេចក្តីសន្និដ្ឋាន** ..............................................................................................................៣៨
**អនុសាសន៍** ...................................................................................................................... ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ស្ថេរភាពនៃនយោបាយបានដើរតួនាទីយ៉ាងសំខាន់សំរាប់ដំណើរការរបស់សង្គមជាតិមួយព្រោះថាវាបាននាំមកនូវសន្តិភាពនិងការអភិវឌ្ឍសំរាប់វិស័យសេដ្ឋកិច្ចក៏ដូចជាវិស័យដទៃទៀតដែរ។ តួយ៉ាងដូចជាប្រទេសកម្ពុជាបានជាប់លំដាប់ថ្នាក់លើគេផ្នែកកំណើនសេដ្ឋកិច្ចដែលកំណើនសេដ្ឋកិច្ចរបស់កម្ពុជាបានកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ៧,៧ភាគរយក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ។បច្ចុប្បន្ននេះកម្ពុជាបានក្លាយជាប្រទេសដែលរីកលូតលាស់លឿនជាងគេទី៦នៅក្នុងពិភពលោកក្នុងកំឡុងពេលនេះ។ដោយសារតែស្ថេភាពនៃនយោបាយនិងការអនុវត្តសេដ្ឋកិច្ចបែបទីផ្សាសេរីរបស់ប្រទេសកម្ពុជាបានទាក់ទាញអ្នកវិយោគបរទេសជាច្រើនចូលមកប្រទេសកម្ពុជា កត្តានេះហើយដែលធ្វើឲ្យជីវភាពរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង។

យើងដឹងហើយមិនថាការធ្វើជំនួញធំឬតូចទេពេលខ្លះក៏មានភាពកង្វះខាតមួយគ្រាន់វដើមទន់សំរាប់ធ្វើការបង្វិល ទូទាត់ក៏ដូចជាការពង្រីកនូវអាជីវកម្មដើម្បីឲ្យជំនួញរបស់ខ្លួនរីកចំរើននិងមានស្ថិតស្ថេរបន្តទៅមុខ។ កិច្ចសន្យាខ្ចីប្រាក់នេះគឺជាប្រតិបត្តិការមួយយ៉ាងសំខាន់នៅក្នុងសង្គមផងដែរ មិនថាសង្គមណាជាសង្គមណាទេពីព្រោះវាមានទំនាក់ទំនងជាមួយប្រជាពលរដ្ឋទូទៅជាប្រចាំ។មួយវិញទៀតប្រតិបត្តិការនេះមិនមែនប្រើតែក្នុងជំនួញជួញដូរទេ កិច្ចសន្យានេះទៀតសោតក៏ប្រើសំរាប់តម្រូវការរបស់ប្រជាជនដូចជាការខ្ចីជាវត្ថុ ស្បៀងអាហារប្រាក់កាក់ផ្សេងៗដើម្បីធ្វើការដោះដូរនិងខ្ចីទៅវិញទៅមកដែលជាមធ្យោបាយក្នុងការទូទាត់ទំនិញប្រចាំថ្ងៃសំរាប់ជាការរស់នៅ។យ៉ាងណាមិញប្រតិបត្តិការនេះពុំមែនទើបតែកើតមានក្នុងសង្គមខ្មែរទេ ពោលគឺវាមានតាំងពីសម័យបុរាណមកម្ល៉េះដែលយើងនឹងធ្វើការបកស្រាយនិងពន្យល់ឲ្យកាន់តែលម្អិតនៅជំពូកបន្តបន្ទាប់។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដូចដែលបានរៀបរាប់ខាងលើយើងដឹងហើយថាកិច្ចសន្យាខ្ចីបរិភោគគឺជាកិច្ចសន្យាដែលមានប្រតិបត្តិការទូលាយក្នុងជីវភាពរស់នៅប្រចាំថ្ងៃប៉ុន្តែភាពយល់ដឹងក្នុងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅតែមានកំរិតពោលគឺមិនបានស្វែងយល់ឲ្យច្បាស់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្នុងប្រតិបត្តិការនេះ ជាពិសេសគឺអ្នកខ្ចីជាកូនបំណុលដែលយើងសង្កេតឃើញមានការទទួលរងនូវការកេងប្រវ័ញ្ចធ្ងន់ធ្ងរទៅលើអត្រាការប្រាក់ដែលភាគីម្ខាងដែលជាម្ចាស់បំណុលតែងកំរិតខ្ពស់លើសអត្រាការប្រាក់ដែលលើសនឹងអ្វីដែលច្បាប់បានកំណត់។ ការមិនទូទាត់សងទៅឲ្យម្ចាស់បំណុលតាមការកំណត់ ការក្លែងបន្លំឯកសារក្នុងកិច្ចសន្យាជាដើម កត្តានេះហើយ

ដែលតែងបង្កើតនូវទំនាស់ជាច្រើនក្នុងប្រតិបត្តិការនេះហើយពេលខ្លះអាចឈានទៅដល់អំពើហិង្សាឬអំពើឃាតកម្មក៏មាន។ទាំងនេះហើយជាចំនុចដែលយើងត្រូវសិក្សានិងយកចិត្តទុកដាក់ជាពិសេសគឺត្រូវបញ្ជ្រាបច្បាប់ទាំងនេះទៅកាន់ប្រជាពលរដ្ឋឲ្យកាន់តែទូលាយដើម្បីកាត់បន្ថយបញ្ហាក៏ដូចជាភាពអសកម្មទាំងឡាយដែលកើតមានក្នុងប្រតិបត្តិការនេះ។

## ៣.គោលបំណងនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅកាន់ចំណោទបញ្ហាស្រាវជ្រាវខាងលើ ក្រុមយើងខ្ញុំធ្វើការចងក្រងដោយមានគោលបំណងផ្តោតសំខាន់លើ៖

- ស្វែងយល់អំពីប្រវត្តិនិងសញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគនៅកម្ពុជា
- ស្វែងយល់អំពីលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ
- ស្វែងយល់យល់អំពីសិទ្ធិនិងកាតព្វកិច្ចនៃគូភាគីក្នុងកិច្ចសន្យាខ្ចីបរិភោគ
- សិក្សាទៅលើបញ្ហាទូទៅដែលកើតមានក្នុងកិច្ចសន្យាខ្ចីបរិភោគ

## ៤.ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទស្តីអំពីកិច្ចសន្យាខ្ចីបរិភោគនេះគឺធ្វើឡើងដោយអនុលោមតាមគោលការណ៍និងការចង្អុលបង្ហាញរបស់សាកលវិទ្យាល័យ។ដោយពេលវេលាយើងមានកំណត់ការសិក្សាស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើប្រភេទ អត្រាការប្រាក់ រយៈពេល កាតព្វកិច្ចរបស់គូភាគីនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលអនុលោមតាមបទ បញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ប្រកាសស្តីពីអត្រាការប្រាក់ និងគោលការណ៍ជាច្រើនទៀតដែលចងក្រងដោយក្រសួងយុត្តិធម៌។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានអ្វីក៏ដោយ វាពិតជាមិនភាពងាយស្រួលទេ ព្រោះវាត្រូវការលះបង់នូវពេលវេលា កម្លាំកាយចិត្ត ប្រាក់កាក់ជាដើមទើបអាចឲ្យយើងទទួលបាននូវភាពជោគជ័យ ដូចសុភាសិតមួយឃ្លាដែលបានពោលថា ៖ "ម្រឹកទាំងឡាយមិនដែលបោលចូលមាត់សីហៈដែលដេកលក់ឡើយ"។មួយវិញទៀតបូកផ្សំជាមួយនិងស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្នក៏ដូចជាពិភពលោកទាំងមូលកំពុងជួបប្រទះនូវវិបត្តិកូវីដ១៩ វាកាន់តែបន្ថែមនូវភាពលំបាកមួយទៀតក្នុងការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ។

ទោះបីជាជួបនូវឧបសគ្គយ៉ាងណាក្តីក៏ក្រុមយើងខ្ញុំនៅតែតស៊ូជំនះវាឲ្យទាល់តែបានព្រោះវាផ្តល់នូវតាវកាលិកយ៉ាងច្រើនសំរាប់ក្រុមយើងខ្ញុំ៖

- ពង្រឹងនូវសមត្ថភាពស្រាវជ្រាវ

- យល់ដឹងកាន់តែច្បាស់អំពីប្រធានបទស្រាវជ្រាវ
- ធ្វើឲ្យយើងចេះវិភាគទៅលើទិន្នន័យដែលប្រមូលបាន
- ចេះស្វែងរកនូវចំណុចខ្សោយ ខ្លាំង និងបញ្ហាប្រឈមដើម្បីរកវិធីក្នុងការដោះស្រាយ
- បានប្រើចំណេះវិជ្ជាដែលរៀនរួចទៅធ្វើការពិសោធន៍នៅក្នុងតថភាពជាក់ស្តែង
- ទទួលបានការចង្អុលបង្ហាញពីអ្នកដែលមានបទពិសោធន៍និងជំនាញច្បាស់លាស់
- បន្សល់ទុកស្នាដៃដើម្បីឲ្យសិស្សប្អូនជំនាន់ក្រោយសិក្សាបន្ត

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការស្រាវជ្រាវក្រុមយើងខ្ញុំបានខិតខំប្រើប្រាស់នូវមធ្យោបាយជាច្រើនក្នុងការស្រាវជ្រាវ ដើម្បីធ្វើការចងក្រងនិងសរសេរសារណានេះឲ្យបានល្អដែលវិធីសាស្ត្រទាំងនោះរួមមាន៖

- ចុះទៅជួបផ្ទាល់ជាមួយអ្នកអនុវត្តន៍ជាក់ស្តែងដើម្បីប្រមូលព័ត៌មាន។
- ស្រាវជ្រាវតាមឯកសារដែលពាក់ព័ន្ធរួមមាន ក្រមរដ្ឋប្បវេណី សៀវភៅពន្យល់ក្រម ប្រកាសស្តីពីអត្រាការប្រាក់ដែលកំណត់ដោយក្រសួងយុត្តិធម៌ជាដើម។
- ការណែនាំចង្អុលបង្ហាញពីសាស្ត្រាចារ្យណែនាំ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទស្តីពី កិច្ចសន្យាខ្ចីបរិភោគនេះត្រូវចែកជា៣ជំពូកធំៗដូចជា៖

ជំពូកទី១ ប្រវត្តិនិងសញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ

១. ប្រវត្តិនៃកិច្ចសន្យាខ្ចីបរិភោគ

២. សញ្ញាណនៃកិច្ចសន្យាខ្ចីបរិភោគ

ជំពូកទី២ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ

ជំពូកទី៣ ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ

# ជំពូកទី ១

## ប្រវត្តិនិងសញ្ញាណទូទៅនៃកិច្ច

## សន្យាខ្ចីបរិភោគ

# ជំពូកទី១

# ប្រវត្តិនិងសញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ

## ១.ប្រវត្តិនៃកិច្ចសន្យាខ្ចីបរិភោគ

ការខ្ចីបុល គឺជាសកម្មភាពមួយដែលកើតមានឡើងតាំងពីបុរាណកាល តាំងពីយូរយាណាស់មកហើយក្នុងគ្រប់សង្គមមនុស្ស។ វាកើតមានតាំងពីសង្គមមនុស្សចេះផលិតរបស់របរនិងជួញដូរ។ នៅក្នុងសង្គមមនុស្សតែងតែមានមនុស្សដែលសល់លុយជាបណ្ដោះអាសន្ននិងអ្នកដែលខ្វះលុយជាបណ្ដោះអាសន្នដោយសារមូលហេតុផ្សេងៗ នៅពេលនោះហើយ ដែលមានតម្រូវការក្នុងការខ្ចីបុលដើម្បីយកមកប្រើប្រាស់។

នៅចន្លោះឆ្នាំ **១៨៦៣** ដល់ ឆ្នាំ **១៩៥៣** កម្ពុជាបានស្ថិតក្រោមអាណានិគមរបស់បារាំង។ អនុសញ្ញាឆ្នាំ **១៨៨៤** រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសបារាំងបានផ្ទេរ ឬ ប្រគល់អំណាចផ្នែករដ្ឋបាលរបស់រដ្ឋឲ្យទៅបារាំង។ នៅពេលនោះប្រជាពលរដ្ឋខ្មែរស្ទើរតែទាំងអស់មានវិបត្តិមួយគឺដើរមិនទាន់របបមូលធនព្រោះថាមុនបារាំងចូលមកប្រជាជនយើងរស់នៅលក្ខណៈបែបប្រពៃណីដោះដូរត្រឹមតែប្រចាំថ្ងៃមិនមែនជាលក្ខណៈបែបមូលធននិយម។ នៅពេលដែលបារាំងចាប់ផ្ដើមប្រមូលពន្ធ ចាប់ផ្ដើមបង្កើតទីផ្សារ ដែលពិបាកក្នុងការរស់នៅធ្វើឲ្យប្រជាជនភាគច្រើនបានបង្ខំចិត្តទៅខ្ចីបុល។ ពេលនោះមានកុងស៊ីបញ្ចាំជាច្រើន ហើយកុងស៊ីបញ្ចាំនៅសម័យនោះភាគច្រើនជាជនជាតិចិន នៅពេលដែលប្រជាជនខ្មែរទៅខ្ចីប្រាក់គឺការប្រាក់ក្នុង១រដូវស្ថិតក្នុងរង្វង់ពី១០០%-១៥០% គឺអត្រាការប្រាក់ខ្ពស់ខ្លាំងណាស់ ដែលពេលនោះដីធ្លីភាគច្រើនរបស់ខ្មែរបានក្លាយជាកម្មសិទ្ធិរបស់ចិនមានន័យថាដីខ្មែរបានជាប់ក្នុងកុងស៊ីអស់ហើយ។ ឃើញស្ថានភាពបែបនេះបារាំងបានចេញច្បាប់មួយគឺកំណត់យកអត្រាការប្រាក់មិនលើសពី៣០%ក្នុង១រដូវ។ ប៉ុន្តែយន្តការនេះមានតែលើក្រដាស ការអនុវត្តជាក់ស្តែងមិនមែនបែបនេះទេ ព្រោះថានៅពេលប្រជាជនទៅខ្ចីប្រាក់នៅកុងស៊ីម្ចាស់កុងស៊ីថាមិនមានប្រាក់ទេ ប៉ុន្តែបើទៅខ្ចីតាមទ្វារក្រោយគឺមានប៉ុន្តែការប្រាក់គឺដដែល១០០%-១៥០%។ដែលជាហេតុធ្វើឲ្យការរស់នៅនៅសម័យនោះពិបាកណាស់[1]។

ក្នុងឆ្នាំ **១៩២០** ក្រមរដ្ឋប្បវេណីកម្ពុជាត្រូវបានប្រកាសឲ្យប្រើ។ ក្នុងនោះក៏បានចែងអំពីកិច្ចសន្យាខ្ចីបរិភោគដែរប៉ុន្តែការកំណត់នៅសម័យនោះមិនសូវទូលាយដូចបច្ចុប្បន្នទេ។ គេបានចែងថាជាការជួលទុន ឬចងការចំពោះ

[1] ដកស្រង់ពីកិច្ចសម្ភាសន៍កម្មវិធីច្បាប់ (កិច្ចសន្យាខ្ចីបរិភោគ) នៅស្ថានីយបាយ័នវាង លោកម៉ែន អេងដែលជាពិធីករ និង លោកមេធាវីអ៊ាង សុភក្ត្រ័

អត្រាការប្រាក់គឺគូភាគីមិនអាចព្រមព្រៀងគ្នាយកការឲ្យហួសពី៨%ក្នុងមួយឆ្នាំនោះឡើយ[2]។អ្វីដែលប្លែកពីការខ្ចីនៅសម័យបច្ចុប្បន្ននោះគឺបើម្ចាស់យកការប្រាក់ហួសពីអត្រាដែលច្បាប់កំណត់ ម្ចាស់នោះត្រូវមានទោសតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ [3] ។ដែលបច្ចុប្បន្នការខ្ចីប្រាក់ខុសពីអត្រាដែលច្បាប់កំនត់មិនមានទោសក្នុងរឿងព្រហ្មទណ្ឌឡើយ។ មួយទៀតគឺការឲ្យខ្ចីបរិភោគវត្ថុដែលក្នុងនោះមិនបានកំណត់អត្រាកាប្រាក់ទេ គ្រាន់មានចែងថាអ្នកខ្ចីត្រូវរកវត្ថុដែលមានធុន មានគុណភាពនិងមានចំនួនដូចគ្នាសងគេតែប៉ុណ្ណោះ[4]។ ចំពោះការឲ្យខ្ចីវត្ថុ គឺមិនមានយកការទេ[5]។

អំឡុងពេលទទួលបានឯករាជ្យពេញលេញ ឆ្នាំ ១៩៥៣-១៩៧៥ ក្រោមស្នាព្រះហស្តបូជនីយ៍កិច្ចរបស់ព្រះបាទ នរោត្តម សីហនុ ប្រទេសកម្ពុជានៅតែបន្តប្រើប្រាស់បទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ដដែល។ កាលនៅសម័យសង្គមរាស្ត្រនិយម រដ្ឋាភិបាលព្យាយាមបង្កើតប្រព័ន្ធឥណទានជនបទ តាមរយៈការបង្កើត "**រាជមន្ទីរសហការយើង**" ការបង្កើតសហករណ៍ផ្តល់ទុន និងការបង្កើតសហករណ៍ឧបភោគបរិភោគជាដើម។ ល ។ នេះជាប្រព័ន្ធដែលគ្រប់គ្រងដោយរដ្ឋ។ រដ្ឋបានលូកដៃចូលយ៉ាងជ្រៅទៅធ្វើអន្តរាគមន៍ ទៅក្នុងការគ្រប់គ្រង។ ក្រោយពីដំណើរការមួយរយៈពេល ប្រព័ន្ធនេះដើរទៅមិនរួចហើយទីបំផុតក៏បរាជ័យមិនអាចដំណើរការធ្វើហិរញ្ញប្បទានបាន[6]។

ក្នុងសម័យកាលឆ្នាំ១៩៧៥-១៩៧៩ កម្មសិទ្ធិឯកជនទាំងឡាយត្រូវបានហាមឃាត់។ ស្បៀងអាហារ សម្ភារៈទ្រព្យសម្បត្តិផ្សេងៗត្រូវបានបញ្ចូលទៅជាទ្រព្យសម្បត្តិសមូហភាព រូបិយបណ្ណត្រូវលុបបំបាត់ចោល។ ការជួញដូរ រឺ ពាណិជ្ជកម្មក្នុងស្រុកត្រូវបានធ្វើតាមរយៈការដោះដូររបស់គ្នាតែប៉ុណ្ណោះ ស្រូវត្រូវបានវាល់ជាកំប៉ុង ហើយបានក្លាយជាការដោះដូរជាធម្មតាសំខាន់បំផុត ទោះបីជាអញ្ចឹងក៏ដោយក៏ប្រជាជនខ្លះដោះដូរមាស គ្រឿងអលង្ការ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដទៃទៀតដែរ។ប៉ុន្តែសកម្មភាពបែបនេះមានតិចតួចណាស់វាស្ទើរតែមិនមាន ព្រោះថានៅសម័យនោះគឺការរស់នៅស្ថិតក្នុងគោលការណ៍ ហូបរួម ដេករួម ធ្វើការរួម។ ដូចច្នេះយើងអាចសន្និដ្ឋានបានថានៅសម័យនោះមិនសូវមានសកម្មភាពខ្ចីកើតឡើងទេ។

---

[2] មាត្រា១១៨៧ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០

[3] មាត្រា១១៨៨ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០

[4] មាត្រា១២០៦ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០

[5] មាត្រា១១៩៥ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០

[6] ដកស្រង់ពី សុន្ទរកថាឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជាថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយអំពីសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជានៅខេត្តសៀមរាបនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥។

បន្ទាប់ពីពួកកុម្មុយនិស្តខ្មែរក្រហមត្រូវបានផ្តួលរលំនៅខែមករាឆ្នាំ១៩៧៩មានការដោះដូរគ្នារវាងអង្ករជាមួយនឹងវត្ថុមានតម្លៃ ជាពិសេសមាស ដើម្បីដោះស្រាយគ្រោះទុរ្ភិក្សនិងខ្ចីគ្នាទៅវិញ។ នៅឆ្នាំ១៩៨០ ប្រព័ន្ធធនាគារថ្មីមួយត្រូវបានបង្កើតឡើង ជាប្រព័ន្ធធនាគារមួយថ្នាក់។ ប្រព័ន្ធឥណទានត្រូវបានគ្រប់គ្រងដោយរដ្ឋ។ បរិមាណទុននិងអត្រាការប្រាក់ត្រូវកំណត់ដោយរដ្ឋ ដើម្បីជៀសវាងពីការកេងប្រវ័ញ្ចពីអ្នកខ្ចី។ នៅទីបំផុតប្រព័ន្ធនេះក៏ដំណើរការដោយមិនមានប្រសិទ្ធិភាព តម្លាភាព និងសមធម៌។ អ្នកខ្ចីបានចេះតែបាន អ្នកខ្ចីមិនបាននៅតែមិនបានខ្ចី ទីបំផុតអ្នកខ្ចីកេងប្រវ័ញ្ចពីរដ្ឋទៅវិញ។ បំណុលជាច្រើនក្លាយជាបំណុលអាក្រក់ទារវិញមិនបានដែលធ្វើឲ្យរដ្ឋបាត់បង់ទុនយ៉ាងច្រើនក្នុងក្រឹត្យច្បាប់សម័យសាធារណរដ្ឋមានិតកម្ពុជាស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យាបានចែងអំពីការខ្ចីដោយមានការប្រាក់ដែលក្នុងសម័យនោះអត្រាការប្រាក់គឺមិនឲ្យលើសពី៥ភាគរយក្នុងមួយឆ្នាំចំពោះកិច្ចសន្យាដែលមិនកំណត់ថ្លៃសង និងមិនកំណត់ការប្រាក់ទេនោះ សន្មតថាគូភាគីព្រមព្រៀងចុះកិច្ចសន្យាសំរាប់រយៈពេល១ឆ្នាំ ដោយគ្មានការប្រាក់[7]។

នៅក្នុងឆ្នាំ១៩៩៣ កម្ពុជាក្លាយជាព្រះរាជាណាចក្រកម្ពុជាមួយ ហើយបានបង្កើតរដ្ឋាភិបាលថ្មីមួយជាមួយនឹងការប្រកាសរដ្ឋធម្មនុញ្ញថ្មី។ ប៉ុន្តែច្បាប់ផ្សេងភាគច្រើនអនុវត្តតាមច្បាប់ចាស់គឺច្បាប់នៅសម័យសាធារណរដ្ឋ។ នៅឆ្នាំ២០០៧ក្រោមការជួយរបស់ប្រទេសជប៉ុនយើងចាប់ផ្តើមមានក្រមរដ្ឋប្បវេណីច្បាស់លាស់មួយដែលអនុវត្តរហូតដល់សព្វថ្ងៃ។

## ២.សញ្ញាណនៃកិច្ចសន្យាខ្ចីបរិភោគ

នៅក្នុងប្រទេសកម្ពុជាយើងការខ្ចីគឺជាប្រត្តិបត្តិការមួយដែលនិយមនិងតែងកើតមានក្នុងជីវភាពរបស់ប្រជាពលរដ្ឋ។សកម្មភាពនេះគឺវាមានតាំងពីយូរលង់ណាស់មកហើយ ហើយវាក៏បាននឹងកំពុងបន្តអនុវត្តនាពេលបច្ចុប្បន្ន។ កម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគយើងធ្វើការបែងចែកទៅតាមប្រភេទរបស់វា។ ដើម្បីជាស្ពានឈានទៅរកការបកស្រាយប្រធានខាងលើឲ្យកាន់តែច្បាស់លាស់និងក្បោះក្បាយថែមមួយកំរិតទៀតនោះ យើងគប្បីស្វែងយល់ន័យនៃពាក្យ ˝កិច្ចសន្យាខ្ចីបរិភោគ˝ ទៅតាមអត្ថន័យនៃអក្សរសាស្ត្រខ្មែរនិងនីតិសាស្ត្រជាមុនសិន។

[7] មាត្រា ៥៨ នៃក្រឹត្យច្បាប់ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា

### ២.១.១ និយមន័យតាមអក្សរសាស្ត្រខ្មែរ

កិច្ចសន្យាខ្ចីបរិភោគមកពីពាក្យថា៖ កិច្ចសន្យា + ខ្ចី + បរិភោគ ។ បើយោងទៅតាមវចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជជួនណាត កិច្ចសន្យាមានន័យថា កិច្ចដែលបានណាត់គ្នា, ដែលបានសន្មតគ្នា។ ខ្ចីមានន័យថា យកពីគេមកប្រើហើយឲ្យទៅវិញ។ ចំណែកឯពាក្យបរិភោគមានន័យថា ការចម្អែតអាត្មា ការប្រើប្រាស់នូវទ្រព្យសម្បត្តិ ឬ គ្រឿងប្រើផ្សេងៗ។ តាមបណ្តាន័យនៃពាក្យខាងលើយើងអាចសន្មតកំណត់បានន័យប្រធានថា កិច្ចសន្យាខ្ចីបរិភោគគឺជាកិច្ចសន្មតគ្នារវាងបុគ្គលពីរនាក់ ឬច្រើនអ្នកគឺភាគីម្ខាងនឹងយកនូវគ្រឿងចម្អែតក្រពះ គ្រឿងប្រើប្រាស់ ឬ ទ្រព្យសម្បត្តិពីភាគីម្ខាងទៀតមកប្រើប្រាស់ដោយសន្មតនឹងសងទៅភាគីដែលឲ្យខ្ចី។

### ២.១.២ និយមន័យតាមនីតិសាស្ត្រ

ផ្អែកទៅតាមនិយមន័យក្នុងក្រមរដ្ឋប្បវេណីមាត្រា៥៧៨បានបញ្ញត្តិថា កិច្ចសន្យាខ្ចីបរិភោគគឺសំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកខ្ចីមានករណីកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងៗទៀតក្នុងអំឡុងពេលដែលបានកំណត់ឱ្យទៅភាគីម្ខាងទៀតហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឲ្យអ្នកឲ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាពនិងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ។

### ២.១.៣ កម្មវត្ថុ

#### ក. ប្រាក់

ប្រាក់សំដៅទៅលើរូបិយវត្ថុដែលមានតម្លៃហើយអាចចរាចរបាន។ វាគឺជាផលិតផលដ៏សំខាន់មួយនៅក្នុងទីផ្សារសេដ្ឋកិច្ច ដើម្បីបង្កើតលក្ខណៈងាយស្រួលដល់ដំណើរការដោះដូរទំនិញ ឬសេវាកម្ម។ រូបិយវត្ថុ ជាវត្ថុមួយដែលត្រូវបានគេប្រើប្រាស់ជាមធ្យោបាយដើម្បី ដោះដូរទំនិញ ឬសេវាកម្ម និងទូទាត់បំណុលផ្សេងៗទៀត។ រូបិយវត្ថុ ក៏ជាអ្វីៗដែលត្រូវបានគេទទួលស្គាល់ក្នុងការទូទាត់ជាមួយទំនិញ ឬសេវាកម្ម និងទូទាត់បំណុលផ្សេងៗទៀត។ រាល់រូបិយវត្ថុបរទេសត្រូវគិតទៅតាមអត្រាប្តូរប្រាក់របស់ធគារជាតិ។

ឧទាហរណ៍៖ ប្រាក់រៀល ប្រាក់ដុល្លា ប្រាក់យេន...

ករណីកម្មវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជាប្រាក់៖ បើកិច្ចសន្យាដែលកម្មវត្ថុជាតាវកាលិកស្នាដៃរបស់មនុស្ស តម្លៃនៃការងារមិនចាំបាច់កំណត់មុនក៏បាន ដូចជាមាត្រា៧២ នៃក្រិត្យច្បាប់លេខ៣៨៖កិច្ចសន្យាសហគ្រាសជាកិច្ចសន្យាដែលបុគ្គលម្នាក់ៗទទួលបន្ទុកធ្វើការងារអ្វីមួយឲ្យបុគ្គលម្នាក់ទៀតដោយយកថ្លៃសមស្របនឹងទំហំនៃការងារនោះ។ ក្នុងមាត្រា៧២ នេះបញ្ជាក់ថា ថ្លៃការងារអាចនឹងមិនកំណត់ក្នុងកិច្ចសន្យាបាន ព្រោះមាត្រានៃក្រឹត្យច្បាប់នេះបានបញ្ជាក់ថា ប្រសិនបើថ្លៃការងារមិនបានកំណត់ក្នុងកិច្ចសន្យា តុលាការត្រូវវិនិច្ឆ័យកំណត់ថ្លៃទៅតាមទំហំនៃកន្លែងធ្វើការនោះ។

**ខ. ស្បៀងអាហារ**

សំដៅទៅលើវត្ថុដែលអាចបរិភោគបាន ត្រូវគូសបញ្ជាក់ថាវត្ថុជាស្បៀងអាហារទាំងនោះត្រូវចែងឲ្យប្រាកដដោយឡែកពីគ្នាទៅតាម ប្រភេទ បរិមាណ និងគុណភាពរបស់វា។

ឧទាហរណ៍៖ បើកម្មវត្ថុនៃកិច្ចសន្យាជាអង្ករ ត្រូវកំនត់ប្រភេទស្រូវ ទំងន់ប៉ុន្មាន។ល។

**គ. វត្ថុជំនួសផ្សេងៗ**

វត្ថុដែលត្រូវខ្ចីបរិភោគត្រូវតែជាវត្ថុមួយដែលជាក់លាក់ដែលអាចធ្វើកិច្ចសន្យាខ្ចីបរិភោគបានធ្វើការសំគាល់ ឬ ក៏អាចកំណត់ជាក់លាក់នៅរូបរាង បរិមាណ និង គុណភាព ។ វត្ថុ ក្នុងន័យនេះអាចជាចលនវត្ថុ និងអចលនវត្ថុ។

វត្ថុក្នុងកិច្ចសន្យាមានពីរប្រភេទ ដូចខាងក្រោម៖

- ចលនវត្ថុ ៖ គឺជាវត្ថុដែលអាចផ្លាស់ប្តូរទីកន្លែងបាន។ ឧ. កង ម៉ូតូ ឡាន សៀវភៅ តុ កៅអី ជាដើម ។ល។
- អចលនវត្ថុ ៖ គឺជាវត្ថុដែលមានស្ថានភាពជាប់នឹងកន្លែងតែមួយ កំរើកមិនកើត ឬមិនអាចផ្លាស់ប្តូរទីកន្លែងបាន។ ឧ. ដី ផ្ទះ អគារ សំណង់ ជាដើម ។ល។

## ៣.ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ

### ៣.១ កិច្ចសន្យាខ្ចីបរិភោគមានការប្រាក់

ការប្រាក់សំដៅទៅលើចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលត្រូវបានផ្តល់ទៅឲ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុដែលត្រូវបានប្រគល់ឲ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬ វត្ថុដែលបានខ្ចីមកគុណនឹងអត្រាដែលត្រូវបានកំណត់[៥]។ វត្ថុដែលផ្តល់ឲ្យអ្នកខ្ចីហៅថាប្រាក់ដើម ចំណែកការប្រាក់ជាផលស៊ីវិល។

កិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ គឺអ្នកឲ្យខ្ចីត្រូវមានករណីយកិច្ចប្រគល់វត្ថុឲ្យទៅអ្នកខ្ចីហើយវត្ថុដែលប្រគល់នោះត្រូវតែជាវត្ថុដែលគ្មានវិការៈ (វត្ថុដែលមានសភាពល្អធម្មតា)។ ដោយឡែកប្រសិនបើវត្ថុអ្នកឲ្យខ្ចីមានវិការៈហើយបានប្រគល់ទៅឲ្យអ្នកខ្ចី ហើយអ្នកខ្ចីពុំបានដឹងអំពើនៃវិការៈនោះ អ្នកខ្ចីអាចទាមទារឲ្យអ្នកឲ្យខ្ចីប្តូរមកវិញនូវវត្ថុដែលគ្មានវិការៈមកឲ្យខ្លួនបាន។ លើសពីនេះអាចទាមទារសំណងខូចខាតបន្ថែមទៀតផង។

---

[៥] មាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ភាគីនៃកិច្ចសន្យាខ្ចីបរិភោគអាចយកកម្មវត្ថុនៃការសងការប្រាក់មកបង្កើតជាសិទ្ធិលើបំណុលតាមការព្រមព្រៀងបាន។ប៉ុន្តែចំពោះការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃកាប្រាក់ ប្រសិនបើពុំបានធ្វើកិច្ចសន្យាលាយល័ក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចីទេគឺពុំមានអានុភាពឡើយ។

### ៣.២ កិច្ចសន្យាខ្ចីបរិភោគគ្មានការប្រាក់

កិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។ កិច្ចសន្យាប្រភេទនេះគឺត្រូវបានប្រើប្រាស់យ៉ាងទូលាយក្នុងជីវភាពប្រចាំថ្ងៃ តួយ៉ាងដូចជាការខ្ចីគ្នាទៅវិញទៅមករវាងមិត្តភក្តិ សាច់ញាតិជាដើម។ ចំពោះកិច្ចសន្យាដែលធ្វើឡើងជាលាយលក្ខណ៍អក្សរអ្នកឲ្យខ្ចីមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការឲ្យខ្ចីនោះទៅតាមការព្រមព្រៀង។ ប៉ុន្តែក្នុងករណីដែលធ្វើឡើងដោយផ្ទាល់មាត់ ប្រសិនបើអ្នកឲ្យខ្ចីពុំទាន់ប្រគល់វត្ថុជាក់លាក់នោះទេ អ្នកឲ្យខ្ចីមានសិទ្ធិបញ្ឈប់កិច្ចសន្យាខ្ចីបរិភោគដោយមិនចាំបាច់មានមូលហេតុច្បាស់លាស់។

# ជំពូកទី ២

## លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ

# ជំពូកទី២

# លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ

## ១. ការបង្កើតកិច្ចសន្យា

### ១.១ ការបង្កើតកិច្ចសន្យាដោយសំណើនិងស្វីការ

#### ១.១.១ គោលការណ៍

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។[9] ជាទូទៅការបង្កើតកិច្ចសន្យាគឺជាគោលការណ៍សេរីភាពរបស់បុគ្គលក្នុងការព្រមព្រៀងអ្វីមួយហើយការព្រមព្រៀងនេះត្រូវតែទទួលស្គាល់ទៅតាមច្បាប់ដែលបានកំណត់។ មួយវិញទៀតគេអាចសន្មតថាកិច្ចសន្យាមួយមានអានុភាពលុះត្រាតែសំណើនិងស្វីការត្រូវគ្នា។[10]

#### ១.១.២ ករណីលើកលែង

ចំពោះកិច្ចសន្យាដែលទាក់ទងនឹងការធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនៃអចលនវត្ថុ វាអាចមានអានុភាពទៅបានលុះត្រាតែបានធ្វើលិខិតយថាភូត។[11]

### ១.២ និយមន័យសំណើនិងស្វីការ

#### ១.២.១ និយមន័យសំណើ

សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[12]

ឧទាហរណ៍ៈ អ្នកស្រី (ក) ដោយសារតែត្រូវការលុយបង្វិលក្នុងអាជីវកម្មរបស់ខ្លួន គាត់ក៏បានទៅសុំខ្ចីលុយពីលោក (ខ) ចំនួន១ពាន់ដុល្លាដោយសន្យាថានឹងសងនៅរយៈពេល៣ខែខាងមុខ ដោយភ្ជាប់ជាមួយការប្រាក់សរុប៥០ដុល្លា។ ការស្នើរសុំខ្ចីលុយរបស់អ្នកស្រី (ក) នេះហៅថា **សំណើ**។

[9] មាត្រា៣១១ (និយមន័យនៃកិច្ចសន្យា) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[10] មើលមាត្រា៣៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[11] មាត្រា៣៣៦កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[12] មាត្រា៣៣៧កថាខណ្ឌទី១(និយមន័យសំណើនិងស្វីការ) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.២.២ ភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ

ទោះបីជាមានចែងច្បាស់ពីនិយមន័យនៃសំណើក៏ដោយគេពិនិត្យឃើញមានភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ។ សំណើគឺជាការបង្ហាញឆន្ទៈថានឹងភ្ជាប់ជាមួយចំណងនៃកិច្ចសន្យា ក្នុងករណីដែលភាគីម្ខាងផ្តល់ស្ទីការឲ្យស្របគ្នាទៅនឹងសំណើនោះ។ ចំណែកការអញ្ជើញឲ្យធ្វើសំណើគឺជាការអញ្ជើញឲ្យភាគីផ្សេងឲ្យសំណើ

មកកាន់ខ្លួន។

ឧទាហរណ៍: ធនាគារ A បានប្រកាសផ្តល់ប្រាក់កម្ចីដល់អ្នកដែលចង់បាន ឬត្រូវការរបស់អ្វីមួយដោយមិនមានពេលគ្រប់គ្រាន់ដើម្បីសន្សំប្រាក់ ដូចជាតម្រូវការយានយន្ត គ្រឿងសង្ហារឹម ការអប់រំជាដើម។ ដោយមិនចាំបាច់មានទ្រព្យបញ្ចាំ។ ធនាគារនឹងធ្វើការគណនាពីលទ្ធភាពខ្ចីរបស់អ្នកខ្ចីដោយផ្អែកទាំងស្រុងទៅលើប្រាក់ចំណូល និងលទ្ធភាពសងមកវិញ។ ជាពិសេសគឺមានអត្រាការប្រាក់ទាបគឺត្រឹមតែ0,៥%ក្នុងមួយខែ។ ការប្រកាសផ្សាយនេះជាការអញ្ជើញឲ្យធ្វើសំណើលើកិច្ចសន្យាខ្ចីប្រាក់ រីឯបុគ្គលដែលមានចំណាប់អារម្មណ៍លើការប្រកាសនោះ ហើយបានដាក់ពាក្យសុំខ្ចីឥណទាន គឺជាការដាក់សំណើរ។ ក្រោយពីធនាគារ A បានពិនិត្យលើពាក្យស្នើរសុំឥណទាន ហើយបានសម្រេចផ្តល់កម្ចីដល់បុគ្គលដែលសុំខ្ចីប្រាក់នោះ គឺជាស្ទីការទៅលើសំណើ ពេលនោះកិច្ចសន្យាខ្ចីប្រាក់នឹងត្រូវបានកើតឡើង។

### ១.២.៣ ពេលដែលបង្កើតអានុភាពនៃសំណើ

សំណើអាចមានអានុភាពទៅបានលុះត្រាតែសំណើនោះបានទៅដល់ភាគីម្ខាងទៀត [13] ។ ដើម្បីឲ្យភាគីម្ខាងទៀតព្រមព្រៀងតាមការសុំបង្កើតកិច្ចសន្យាអ្នកស្នើត្រូវតែសំដែងឆន្ទៈស្មោះត្រង់ សុចរិតពិតប្រាកដដើម្បីឲ្យភាគីព្រមទទួលយកសំណើ។

ឧទាហរណ៍: ធនាគារស្រូវ B មួយបានបញ្ចេញពូជស្រូវចំនួន១0តោន ដើម្បីផ្តល់កម្ចីដល់កសិករដោយឥតការប្រាក់ ។ កសិករ A បានប្រាប់ធនាគារ B ថានឹងខ្ចីពូជស្រូវចំនួន២៥គីឡូ។ ដូចនេះសំណើ A ផ្តល់ទៅឲ្យ B មានអានុភាព។

ប៉ុន្តែប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នានឹងពេលសំណើដល់ឬមុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើងវិញឡើយ។ [14] ការកំណត់បែបនេះដោយហេតុថាករណីនេះមិនបានធ្វើឲ្យភាគីម្ខាងទៀតខូចប្រយោជន៍ឡើយ ពីព្រោះភាគីម្ខាងទៀតពុំទាន់បានធ្វើអ្វីនៅឡើយ។[15]

---

[13] មាត្រា៣៣៧កថាខណ្ឌទី២ វាក្យខណ្ឌទី១ (និយមន័យសំណើរនិងស្ទីការ) នៃក្រមរដ្ឋប្បវេណីឆ្នាំ២00៧

[14] មាត្រា៣៣៧កថាខណ្ឌទី២ វាក្យខណ្ឌទី២ (និយមន័យសំណើរនិងស្ទីការ) នៃក្រមរដ្ឋប្បវេណីឆ្នាំ២00៧

[15] មើមាត្រា៣៣៧ ទំព័រ៣៦ នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី (គន្លឹះទី៤)

ឧទាហរណ៍: ធនាគារស្រូវ B មួយបានបញ្ចេញពូជស្រូវចំនួន១០តោន ដើម្បីផ្ដល់កម្ចីដល់កសិករដោយឥតការប្រាក់ ។ កសិករ A បានស្នើ D ឲ្យទៅប្រាប់ធនាគារ B ថាខ្លួននឹងខ្ចីពូជស្រូវចំនួន២៥គីឡូ។ ក្រោយមកកសិករ A បានស្នើ C ឲ្យជូនដំណឹងទៅធនាគារ B ថាខ្លួនឈប់ខ្ចីពូជស្រូវវិញហើយ (ការដកសំណើរ)។ ករណីនេះប្រសិនបើ C បានប្រាប់ធនាគារ B ពីការឈប់ខ្ចី នៅចំពេល ឬមុនពេលដែល D ប្រាប់ធនាគារ B ពីការខ្ចីស្រូវរបស់ A នោះសំណើរបស់ A តាមរយៈ D មិនមានអានុភាពឡើយ។

**១.២.៤ និយមន័យស្ទីការ**

ស្ទីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។[16]

ឧទាហរណ៍: A បានប្រាប់ទៅកាន់ B ថាខ្លួននឹងសុំខ្ចីលុយពី B ចំនួន ៥០០ដុល្លា ហើយ B បានយល់ព្រមឲ្យ A ខ្ចី។ ការឆ្លើយតបរបស់ B ថាឲ្យ A ខ្ចីគឺជាស្ទីការ។

ករណីបើគ្មានសំណើរទេ ប្រសិនបើបុគ្គលម្នាក់បង្ហាញឆន្ទៈណាមួយទៅភាគីម្ខាងទៀត ការបង្ហាញឆន្ទៈនោះពុំមែនជាស្ទីការទេតែគេបកស្រាយថាជាសំណើរវិញ។

**១.២.៥ សំណើខ្វែង**

សំណើមួយដែលធ្វើឡើងដោយអ្នកណាម្នាក់ ដោយមិនបានដឹងថាអ្នកទទួលសំណើក៏បានដាក់សំណើដូចគ្នាមកកាន់អ្នកស្នើ ករណីនេះហៅថាសំណើខ្វែង។[17]

ឧទាហរណ៍: ដោយសារតែចំការរបស់ A ត្រូវបានខាតបង់ធ្ងន់ធ្ងរដោយសារគ្រោះទឹកជំនន់ A ក៏បានជូនដំណឹងទៅកាន់ B ថានឹងសុំខ្ចីលុយមួយចំនួន។ B ជាមិត្តរបស់ A ក្រោយដឹងដំណឹងបែបនេះក៏អាណិតហើយបានជូនដំណឹងទៅកាន់ A ថានឹងឲ្យខ្ចីលុយមួយចំនួនដើម្បីដោះទាល់ដោយមិនបានដឹងពីការជូនដំណឹងខ្ចីលុយរបស់ A ទេ(សំណើខ្វែង)។ ជាទូទៅទោះបីជាអ្នកទាំងពីបានបង្ហាញឆន្ទៈក៏ដោយក៏កិច្ចសន្យាមិនទាន់កើតមានឡើយ ពីព្រោះពួកគេគ្រាន់តែដាក់សំណើឲ្យគ្នាទៅវិញទៅមកប៉ុណ្ណោះ។ ប៉ុន្តែបើមានស្ទីការពីភាគីណាមួយម្ដងទៀត នោះកិច្ចសន្យានឹងកើតឡើង។ ម្យ៉ាងវិញទៀត មានទស្សនៈថាដោយសារឆន្ទៈរបស់ភាគីទាំងពីត្រូវគ្នាហេតុនេះគួរតែទទួលស្គាល់ថា កិច្ចសន្យានឹងកើតមានបន្ទាប់ពីសំណើក្រោយពេលបានទៅដល់ភាគីម្ខាងទៀត។

**១.២.៦ ពេលដែលបង្កើតអានុភាពនៃស្ទីការ**

មិនខុសពីអានុភាពនៃសំណើទេ អានុភាពនៃស្ទីការ កើតមាននៅពេលដែលស្ទីការនោះទៅដល់អ្នកស្នើ[18]។ យ៉ាងណាមិញ បើដំណឹងពីការដកស្ទីការបានទៅដល់ក្នុងអំឡុងពេល ឬមុនពេលស្ទីការទៅដល់អ្នកស្នើ

[16] មាត្រា៣៣៧កថាខណ្ឌទី៣ (និយមន័យសំណើរនិងស្ទីការ) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[17] Bryan A Garner , Black´s Law Dictionary, 8th ed ( st Paul , Minn West Gruop, 2004),405.

[18] មាត្រា៣៣៧កថាខណ្ឌទី៣ (និយមន័យសំណើរនិងស្ទីការ) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នាំឲ្យស្ទីការនោះមិនមានអានុភាពនោះទេ។ អ្វីដែលសំខាន់នោះគឺស្ទីការត្រូវតែមានខ្លឹមសារនៃសារធាតុដូចគ្នាឬត្រូវគ្នា។ ស្ទីការដែលមានលក្ខខណ្ឌត្រូវនឹងសំណើរគឺជាស្ទីការដែលឆ្លើយតបនិងទទួលយកនូវកម្មវត្ថុតែមួយដែលសំណើបានស្នើឡើង។

ឧទាហរណ៍ៈ សំណើជាការខ្ចីបរិភោគត្រូវតែកំណត់ឲ្យបានច្បាស់អំពីចំនួនដែលត្រូវខ្ចី ការយកការប្រាក់ឬមិនយកការប្រាក់ ប្រសិនជាមានការប្រាក់ត្រូវកំណត់អត្រាការប្រាក់ឲ្យបានច្បាស់លាស់ រយៈពេលដែលនឹងសងជាដើមទាំងនេះគឺជាខ្លឹមសារស្នូលនៅក្នុងសំណើរខ្ចីបរិភោគដើម្បីផ្ញើមកដល់ភាគីម្ខាងទៀតហើយភាគីម្ខាងទៀតត្រូវជូនដំណឹងតាមរយៈស្ទីការទៅគេវិញដោយកំណត់ថាខ្លួនយល់ព្រមឬមិនយល់ព្រមហើយខ្លឹមសារនៃស្ទីការនោះគឺត្រូវឆ្លើយតបនឹងកម្មវត្ថុនៃសំណើរដែលភាគីម្ខាងទៀតបានស្នើមក។

## ២. វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា

### ២.១ ការពិចារណាជាមូលដ្ឋាន

យើងបានដឹងហើយថាកិច្ចសន្យាអាចមានសុពលភាពទៅបានគឺដោយសារតែការបង្ហាញឆន្ទៈរបស់ភាគីទាំងសងខាងស្របគ្នាទៅវិញទៅមក។ ហេតុដូចនេះហើយប្រសិនបើគ្មានការបង្ហាញឆន្ទៈដែលមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទេ កិច្ចសន្យានោះពុំមានចំណងចងភាគីទាំងពីរទេ ទោះបីជាកិច្ចសន្យានោះហាក់ដូចជាត្រូវបានបង្កើតឡើងបើមើលពីខាងក្រៅក៏ដោយ។ ក្នុងន័យនេះ ការបង្ហាញឆន្ទៈដែលមានសុពលភាព គឺជាលក្ខខ័ណ្ឌដើម្បីឲ្យកិច្ចសន្យានោះមានអានុភាពចងភាគីទាំងសងខាងបាន។ ដូចនេះគេត្រូវពិចារណាលើផលប្រយោជន៍របស់ភាគីទាំងពីរដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ។

### ២.២ ការបង្ហាញឆន្ទៈដោយមានវិការៈ

កិច្ចសន្យាត្រូវធ្វើឡើងដោយសុចរិត ស្មោះត្រង់ ដោយសេរីហើយមិនមានវិការៈវាគឺជាការព្រមព្រៀងដោយពិតប្រាកដ។ ដូចនេះរាល់កិច្ចសន្យាទាំងឡាយណាដែលមានវិការៈគឺអាចធ្វើការបដិសេធចោលនូវអានុភាពនៃការបង្ហាញឆន្ទៈ។ ករណីដែលអាចមោឃភាពឬលុបចោលមានដូចជា ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគំរាមគំហែង ការកេងយកចំណេញហួសហេតុ ឋបនីយផ្លូវចិត្ត និងការបង្ហាញឆន្ទៈមិនពិត។ ទាំងនេះគឺជាកត្តាដែលនាំឲ្យមានភាពផ្ទុយពីគោលការណ៍សុចរិតភាពនិងភាពស្មោះត្រង់នៃកិច្ចសន្យា។

## ២.៣ ការភាន់ច្រឡំ

### ២.៣.១ និយមន័យ

- ការភាន់ច្រឡំ មានន័យថា គឺជាការបង្ហាញនូវឆន្ទៈទៅលើកិច្ចសន្យាដោយការយល់ច្រឡំអំពីខ្លឹមសារនៃកិច្ចសន្យា។
- ការយល់ខុសដោយខ្លួនឯងដោយមិនមានអ្នកណាមួយមកបំភាន់ឡើយ។
- គឺជាស្ថានភាពមួយដែលធាតុអត្តនោម័តខាងក្នុង ខុសពីភាពសត្យានុម័តខាងក្រៅ។

### ២.៣.២ ប្រភេទនៃការភាន់ច្រឡំ

#### ក. ការភាន់ច្រឡំក្នុងកិច្ចសន្យា

លក្ខខណ្ឌនៃការភាន់ច្រឡំមានដូចខាងក្រោម៖

- ភាគីមានការភាន់ច្រឡំ
- ចំណុចដែលភាន់ច្រឡំជាចំណុចសំខាន់ក្នុងកិច្ចសន្យា
- ភាគីម្ខាងទៀតបានដឹងពីភាគីដែលមានការភាន់ច្រឡំ

ភាគីដែលមានការភាន់ច្រឡំត្រូវបានអនុញ្ញាតឲ្យលុបចោលកិច្ចសន្យាក្នុងល័ក្ខខណ្ឌដែលមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ហើយភាគីម្ខាងទៀតអាចដឹងថាមានការភាន់ច្រឡំ[19]។

តើចំណុចសំខាន់ៗនៃកិច្ចសន្យាជាអ្វី? វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគគឺជាចំណុចសំខាន់នៃកិច្ចសន្យា។

ឧទាហរណ៍៖ ក បានបង្កើតកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាពូជស្រូវជាមួយ ខ ដោយខ្លួនយល់ថាគ្រាប់ពូជស្រូវរបស់ ខ ជាពូជស្រូវខ្មែរមានរសជាតិឆ្ងាញ់ គ្រាប់រលូន។ ប៉ុន្តែនៅថ្ងៃបន្ទាប់លោក ក គាត់បានដឹងថាគ្រាប់ពូជរបស់ ខ មិនមែនជាគ្រាប់ពូជស្រូវខ្មែរទេ វាជាគ្រាប់ពូជនាំចូលពីវៀតណាម។ ដូចនេះ ក បានលុបកិច្ចសន្យាខ្ចីបរិភោគនោះជាមួយ ខ ។

#### ខ. ការភាន់ច្រឡំរអង្គហេតុសំខាន់ចំពោះភាគីម្ខាង

ល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំរអង្គហេតុសំខាន់ចំពោះភាគីម្ខាងមានដូចខាងក្រោម៖

- ភាគីមានការភាន់ច្រឡំ

[19] នីតិរដ្ឋប្បវេណី គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជាឧបត្ថម្ភដោយអង្គការ JICA សមិទ្ធិផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់ពីឆ្នាំ២០១២-២០១៧

- ភាគីដែលមានការភាន់ច្រឡំ មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។
- ភាគីម្ខាងទៀតបានដឹងពីភាគីដែលភាន់ច្រឡំហើយក៏ដឹងថាចំណុចដែលភាគីភាន់ច្រឡំជាចំណុចសំខាន់របស់ភាគីភាន់ច្រឡំ[20]។

ឧទាហរណ៍ ៖ករណីនៃការខ្ចីបរិភោគអង្ករ ទោះបីជាប្រភេទអង្ករ ( អង្ករស្រូវវស្សា អង្ករស្រូវប្រាំង) ជាធម្មតាមិនសូវសំខាន់ក្នុកិច្ចសន្យាក៏ដោយប៉ុន្តែបើអ្នកខ្ចីចាត់ទុកថា ប្រភេទស្រូវថាជាចំណុចសំខាន់ក្នុងការប្រើប្រាស់របស់គាត់ អ្នកខ្ចីអាចអនុញ្ញាតឲ្យលុបចោលកិច្ចសន្យាដោយហេតុផលនៃការភាន់ច្រឡំអំពីប្រភេទស្រូវ។ ប៉ុន្តែក្នុងល័ក្ខខ័ណ្ឌដែលភាគីម្ខាងទៀតអាចដឹងថាប្រភេទស្រូវគឺជាចំណុចសំខាន់សម្រាប់អ្នកខ្ចីហើយអាចដឹងបានដែរថាអ្នកខ្ចីមានការភាន់ច្រឡំ។

**គ. ការភាន់ច្រឡំរួម**

ល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំរួមមានដូចខាងក្រោម៖

- ភាគីទាំងសងខាងមានការភាន់ច្រឡំ
- ចំណុចដែលមានការភាន់ច្រឡំគឺជាចំណុចសំខាន់ក្នុងកិច្ចសន្យាឬចំណុចដែលភាគីទាំងសងខាងឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា[21]។

ឧទាហរណ៍៖ ក និង ខ សុទ្ធតែជាអ្នកលក់កាតាបដូចគ្នា។ ថ្ងៃមួយមានម៉ូយមករកទិញកាតាបម៉ាក monblan ចំនួន៥ នៅតូប ក តែ ក អត់មានលក់កាតាបម៉ាកនេះទេក៏បានទៅខ្ចីពីតូប ខ យកមកលក់។ ខ បានយកកាតាប monblan ផលិតនៅប្រទេសចិនឲ្យទៅ ក ដោយច្រឡំថាជារបស់ពិត ។ ម៉ាក monblan ពិតគឺផលិតនៅប្រទេសអាឡឺម៉ង់ គឺជាចំណុចសំខាន់ក្នុងកិច្ចសន្យា។ក្នុងករណីនេះកនិងខ មានការភាន់ច្រឡំដូចគ្នា។ ទោះបីជា ក មិនដឹងអំពីការភាន់ច្រឡំរបស់ ខ ក៏ដោយក៏ ខ អាចលុបចោលកិច្ចសន្យានេះបានដែរ។

## ២.៤ ការឆបោក

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈដោយសារការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យាដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

[20] មាត្រា ៣៤៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី

[21] មាត្រា ៣៤៦ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី

ឧទាហរណ៍៖ ក ទៅខ្ចីពូជស្រូវរបស់ ខ ដោយបានប្រាប់ទៅ ក ថានេះជាពូជស្រូវខ្មែរ ១០០% តាមពិតពូជស្រូវនេះគឺ ខ បាននាំចូលពីប្រទេសវៀតណាម។ ដូចនេះ ក មានសិទ្ធិលុបចោលកិច្ចសន្យាដោយផ្អែកលើការឆបោក។

## ២.៥ ព័ត៌មានមិនពិត

ការការពារភាគីបង្ហាញឆន្ទៈដោយផ្អែកលើព័ត៌មានមិនពិតដែលត្រូវបានបង្ហាញដោយភាគីម្ខាងទៀត។ ប្រសិនបើភាគីម្ខាងទៀតបង្ហាញព័ត៌មានមិនពិតដោយចេតនា សកម្មភាពនេះក្លាយជាការឆបោក។ ហេតុដូច្នេះអ្នកបង្ហាញឆន្ទៈត្រូវបានការពារដោយយោងតាមមាត្រា៣៤៧។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀត មិនបានធ្វើដោយចេតនាទេ ការបង្ហាញឆន្ទៈនេះមិនអាចលុបចោលដោយហេតុផលនៃការឆបោកនោះទេ។ម្យ៉ាងទៀតក្នុងករណីដែលព័ត៌មានមិនពិតត្រូវបានបង្ហាញដោយភាគីម្ខាងទៀតមានករណីច្រើនដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ហេតុដូចនេះ ការលុបចោលកិច្ចសន្យាអាចអនុញ្ញាតដោយហេតុផលនៃការភាន់ច្រឡំ។ប៉ុន្តែការលុបចោលនូវកិច្ចសន្យាដោយសារការភាន់ច្រឡំតម្រូវថាការភាន់ច្រឡំត្រូវទាក់ទងនឹងចំណុចសំខាន់ៗនៃកិច្ចសន្យា និងភាគីម្ខាងទៀតត្រូវមានលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំនេះ[22]។

ប្រសិនបើភាគីដែលបង្ហាញព័ត៌មានមិនពិតមានកំហុសក្នុងការបង្ហាញព័ត៌មានមិនពិតនេះ ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត។ ក្នុងករណីនេះ គួរបកស្រាយថា ភាគីដែលទទួលរងនូវការខូចខាត អាចលុបចោលកិច្ចសន្យានិងទាមទារសំណងនៃការខូចខាតដែលនៅសល់ក្រោយការលុបចោលបានឬក៏អាចទាមទារសំណងនៃការខូចខាតដោយមិនលុបចោលកិច្ចសន្យាបានដែរ[23]។

ប្រសិនបើកិច្ចសន្យាត្រូវលុបចោលដោយសារហេតុផលនៃព័ត៌មានមិនពិត អានុភាពនៃការលុបចោលកិច្ចសន្យាអាចតតាំងបាន មិនត្រឹមភាគីម្ខាងទៀតប៉ុណ្ណោះទេ ថែមទាំងតតិយជន ដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់[24]។

ឧទាហរណ៍៖ A បានទៅខ្ចីលុយពី B ចំនួន១ម៉ឺនដុល្លាសន្យាថានឹងសងនៅអាទិត្យក្រោយដោយប្តីខ្លួនខ្វះលុយក្នុងការបង្វិលលើមុខជំនួញរបស់ខ្លួន។ B ដោយហេតុយល់ថា A ជាមនុស្សល្អហើយរាប់អានគ្នាជាច្រើនឆ្នាំក៏យល់ព្រមឲ្យ A ខ្ចី។ ប៉ុន្មានថ្ងៃក្រោយមកមិត្តភក្តិ B ក៏ទៅប្រាប់ថា B ថា ប្តី A បានចាញ់ល្បែងជាប់បំណុលគេច្រើនណាស់។ B ក៏ទៅសួរ Aប៉ុន្តែរឿងនេះ A មិនបានដឹងឡើយ។ ក្រោយពីជីកកកាយសួរប្តីរួចទើប

[22] នីតិរដ្ឋប្បវេណី គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជាឧបត្ថម្ភដោយអង្គការ JICA សមិទ្ធិផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់ពីឆ្នាំ២០១២-២០១៧ ទំព័រ ១១៨

[23] មើលក្រមរដ្ឋប្បវេណី ២០០៧ មាត្រា៣៤៨ កថាខណ្ឌទី២

[24] មើលក្រមរដ្ឋប្បវេណី ២០០៧ មាត្រា៣៤៨ កថាខណ្ឌទី៣

ដឹងរឿងពិត។ ក្នុងករណីនេះ B អាចលុបចោលកិច្ចសន្យាខ្ចីលុយបានព្រោះព័ត៌មានដែល A ផ្តល់ឲ្យ B មិនពិតប្រាកដ។

## ២.៦ ការរំលោភបំពានលើស្ថានភាព

នៅពេលបង្កើតកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀត មិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[25]។

ចំណុចនៃការប្រើប្រាស់នូវស្ថានភាពលំបាករបស់អ្នកបង្ហាញឆន្ទៈគឺស្រដៀងគ្នានឹងអំពើកេងយកចំណេញហួសហេតុ។ ប៉ុន្តែបើប្រៀបធៀបនឹងការកេងយកចំណេញហួសហេតុ ការរំលោភបំពានលើស្ថានភាពមានកម្រិតនៃការគៀបសង្កត់ចំពោះអ្នកបង្ហាញឆន្ទៈខ្លាំងជាងការកេងយកចំណេញហួសហេតុ។ ម្យ៉ាងទៀតទោះបីជាអ្នករំលោភលើស្ថានភាពមិនទទួលបានចំណេញហួសហេតុក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈអាចលុបចោលបានដែរ។

ឧទាហរណ៍៖ A បានជួលដីមុខផ្ទះ ពីB ដើម្បីលក់នំប៉័ងដាក់សាច់។ កន្លងមកកិច្ចសន្យាជួលដីត្រូវធ្វើជារៀងរាល់ឆ្នាំ។ឆ្នាំនេះ A ក៏សង្ឃឹមថា B នឹងធ្វើកិច្ចសន្យាថ្មីដូចសព្វដង។ ប៉ុន្តែ B បានដឹងថា A ជីវភាពរាល់ថ្ងៃគឺពឹងផ្អែកលើមុខរបរនេះហើយ ដូច្នេះ B ក៏បានទៅនិយាយជាមួយ A ថា៖ បើ A មិនព្រមឲ្យខ្ញុំខ្ចីលុយចំនួន ១០០០ដុល្លានោះខ្ញុំនឹងមិនព្រមបន្តជួលដីមុខផ្ទះឲ្យ A ឡើយ។ A អស់ជម្រើសក៏បង្ខំចិត្តឲ្យ B ខ្ចីលុយចំនួន ១០០០ដុល្លា។ A អាចលុបចោលកិច្ចសន្យាខ្ចីប្រាក់បានដោយផ្អែកលើការរំលោភស្ថានភាពនេះ។

## ២.៧ ការគំរាមកំហែង

បុគ្គលដែលបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជនអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[26]។

ស្ថានភាពនៃការគាបសង្កត់ទៅលើឆន្ទៈចំណុចនៃការបង្ហាញឆន្ទៈនោះគឺស្រដៀងគ្នានឹងការរំលោភលើស្ថានភាព និងការកេងយកចំណេញហួសហេតុ។ ប៉ុន្តែ ការរំលោភលើស្ថានភាពនិងការកេងយកចំណេញហួសហេតុគឺគ្រាន់តែប្រើប្រាស់នូវស្ថានភាពលំបាករបស់អ្នកបង្ហាញឆន្ទៈប៉ុណ្ណោះផ្ទុយមកវិញការគម្រាមកំហែងគឺខុសគ្នាត្រង់ចំណុចដែលមានការភ័យខ្លាចដោយសារអំពើគម្រាមកំហែងរបស់អ្នកគម្រាមកំហែង។

ឧទាហរណ៍៖ A និយាយទៅកាន់ B ថាបើមិនចង់ស្លាប់ទេ ឆាប់ឲ្យយើងខ្ចីលុយ ១០០០ដុល្លាទៅ

[25] មាត្រា៣៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[26] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណី ២០០៧

ប្រសិនបើ B ឲ្យលុយចំនួន១០០០ដុល្លានេះទៅ A ខ្ចីដោយសារការភ័យខ្លាចនោះ B អាចលុបចោលកិច្ចសន្យាខ្ចីប្រាក់ដោយផ្អែកលើការគម្រាមកំហែងបាន។

### ២.៨ ការកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឪកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[27]។

ស្រដៀងគ្នានឹងការរំលោភលើស្ថានភាព។ កម្រិតនៃការគាបសង្កត់លើការបង្ហាញឆន្ទៈនៃអំពើកេងចំណេញហួសហេតុគឺទាបជាងការរំលោភលើស្ថានភាពប៉ុន្តែទោះជាកម្រិតនៃការគាបសង្កត់លើការបង្ហាញឆន្ទៈនៃអំពើកេងចំណេញហួសហេតុទាបជាងកម្រិតការរំលោភលើស្ថានភាពក៏ដោយក៏អាចលុបចោលបានដែរ។ ផ្ទុយមកវិញក្នុងករណីដែលអ្នកធ្វើអំពើកេងយកចំណេញហួសហេតុបានចំណេញហួសហេតុ លុះត្រាតែបានទទួលផលចំណេញហួសហេតុនោះប៉ុណ្ណោះទើបអ្នកបង្ហាញឆន្ទៈអាចលុបចោលបាន[28]។

### ២.៩ ឋបនីយផ្លូវចិត្ត

ឋបនីយផ្លូវចិត្តគឺជាការបង្ហាញឆន្ទៈដែលធ្វើឲ្យដឹងថាការបង្ហាញឆន្ទៈនេះមិនពិតទេ។ កិច្ចសន្យាមិនត្រូវបានរារាំងអានុភាពឡើយប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈដែលភាគីដឹងថាខុសឆន្ទៈរបស់ខ្លួនតែអ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបានក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះខុសពីការពិតរបស់អ្នកបង្ហាញឆន្ទៈ។ ក្នុងករណីនេះមិនមែនមានន័យថាកិច្ចសន្យាត្រូវបានបដិសេធអានុភាពនោះទេ។ការបង្ហាញឆន្ទៈដែលធ្វើឡើងដោយឋបនីយផ្លូវចិត្តជាការបង្ហាញឆន្ទៈមិនពិតរបស់ភាគីអ្នកបង្ហាញឆន្ទៈដូចនេះវាជាការបង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលបាន។ ក៏ប៉ុន្តែក្នុងករណីនេះកិច្ចសន្យាគឺមិនអនុញ្ញាតឲ្យលុបចោលបានទេ ទោះបីភាគីម្ខាងទៀតបានដឹងពីការបង្ហាញឆន្ទៈមិនពិតរបស់អ្នកបង្ហាញក៏ដោយក៏សុពលភាពនៃកិច្ចសន្យាត្រូវកើតឡើងដែរពីព្រោះថាការបង្ហាញ[29]។

---

[27] មាត្រ៣៥១ នៃក្រមរដ្ឋប្បវេណី ២០០៧

[28] មើមាត្រា៣៥១ ទំព័រ៣៨ នៃមេរៀនភាគ១ ក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណី សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់និងតុលាការ ក្រសួងយុត្តិធម៌

[29] មើលមាត្រា៣៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

### ២.១០ ការបង្ហាញឆន្ទៈមិនពិត

ដើម្បីបង្កើតកិច្ចសន្យានោះភាគីនៃកិច្ចសន្យាត្រូវតែបង្ហាញឆន្ទៈព្រមគ្នា និងអនុវត្តតាមគ្រប់ចំណុចឬប្រកាសដែលមានចងភ្ជាប់ជាកាតព្វកិច្ចនៃកិច្ចសន្យាគោរពនិងធ្វើតាម។ លើសពីនេះទៅទៀតក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិក្នុងមាត្រាមួយចំនួនថាដើម្បីឲ្យកិច្ចសន្យាមួយមានសុពលភាពលុះត្រាតែកិច្ចសន្យានោះធ្វើឡើងដោយការបង្ហាញឆន្ទៈគ្មានវិការៈពុំដូចនោះទេកិច្ចសន្យានឹងត្រូវបានលុបចោល។ក្នុងក្រមក៏បានបង្ហាញបញ្ញត្តិផងដែរថាការបង្ហាញឆន្ទៈមិនពិតធ្វើឡើងដោយឃុបឃិតជាមួយភាគីម្ខាងទៀតនិងមូលហេតុដែលកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈភាព។ មូលហេតុដែលច្បាប់បញ្ញត្តិបែបនេះពីព្រោះតែចង់ការពារផលប្រយោជន៍ឲ្យតតិយជនដែលជាជនសុចរិតមិនបានដឹងពីការបង្ហាញឆន្ទៈមិនពិតរបស់ភាគីខាងលើនោះឡើយ។ បើតតិយជននេះបានដឹងទំនងជាតតិយជននេះមិនព្រមបង្កើតកិច្ចសន្យានេះឡើយ។ ផ្ទុយទៅវិញបើតតិយជននោះបានដឹងហើយ តែនៅព្រមព្រៀងបង្កើតកិច្ចសន្យាបែបនេះឡើងទៀតនោះកិច្ចសន្យាចាត់ទុកថាមានអានុភាព[30]។

## ៣.សមត្ថភាព

សមត្ថភាពខាងឆន្ទៈគឺជាសមត្ថភាពដែលអាចយល់ដឹងនិងវិនិច្ឆ័យបានអំពីលទ្ធផលតាមច្បាប់នៃសកម្មភាពរបស់ខ្លួន។បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ។ ប៉ុន្តែបុគ្គលគ្រប់រូបមិនមែនសុទ្ធតែអាចធ្វើកិច្ចការជំនួញដែលមានសុពលភាពដោយឯកឯងគ្រប់ពេលនោះទេ។ ឧទាហរណ៍ ទោះបីជាក្មេងអាយុ៣ឆ្នាំនិងបុគ្គលដែលកំពុងតែស្រវឹងខ្លាំងបានសន្យាទិញទំនិញដែលមានតម្លៃថ្លៃក៏ដោយក៏មិនចាំចាច់ត្រូវទទួលស្គាល់នូវអានុភាពនៃកិច្ចសន្យាបែបនេះនោះទេ។ ដូចនេះ ក្រមរដ្ឋប្បវេណីបញ្ញត្តិនូវប្រព័ន្ធសមត្ថភាពខាងឆន្ទៈនេះឡើងដើម្បីអាចលុបចោលនូវសកម្មភាពរបស់បុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ។

### ៣.១ នីតិជន

ក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់អត្ថន័យនៃនីតិជនថាគឺជា បុគ្គលដែលមានអាយុគ្រប់តាមច្បាប់កំណត់ហើយមានសមត្ថភាពឯករាជ្យខាងអំពើពោលគឺជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ បុគ្គលប្រភេទនេះមានសមត្ថភាពក្នុងការចុះកិច្ចសន្យាបានដោយគ្មានត្រូវការការយល់ព្រមពីនរណាម្នាក់ឲ្យតែសកម្មភាពទាំងនោះស្របតាមបទបញ្ញត្តិដែលច្បាប់បានកំនត់ដែលមិនមែនជាកម្មវត្ថុនៃអំពើខុសច្បាប់។

### ៣.២ អនីតិជន

អនីតិជនសំដៅទៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ [31] ។សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល

[30] មើលមាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[31] មាត្រា១៧ (និយមន័យអនីតិជន) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឲ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ[32]។ ពោលគឺសកម្មភាពដែលមានភាពងាយស្រួលក្នុងការវិនិច្ឆ័យជាទូទៅមានតម្លៃទឹកប្រាក់ទាបដែលមិនមានការព្រួយបារម្ភអំពីការខូចខាតផលប្រយោជន៍របស់អនីតិជន។ ធ្វើបែបនេះអនុញ្ញាតឲ្យអនីតិជនមានភាពងាយស្រួលក្នុងការធ្វើសកម្មភាពតែម្នាក់ឯងបានដើម្បីបម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

អនីតិជនអាចធ្វើការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបាឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឲ្យចាត់ចែង ក្នុងទំហំនៃគោលបំណងដែលបានកំណត់ [33]។ ឧទាហរណ៍៖ ម្តាយឲ្យប្រាក់កូនចំនួន១០ដុល្លាដើម្បីទិញភីហ្សា។ ម្យ៉ាងវិញទៀតអនីជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបាឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឲ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ[34]។

ឧទាហរណ៍ ៖ ករណីដែលឪពុកម្តាយបានឲ្យប្រាក់កូន២០ដុល្លា សម្រាប់ចំណាយផ្ទាល់ខ្លួន ដូចនេះ អនីតិជនអាចប្រើប្រាស់២០ដុល្លា នោះដើម្បីទិញទំនិញបាន។

### ៣.៣ អនីតិជនដែលទទួលបានអត្តាធីនភាព

អនីតិជនដែលទទួលបានអត្តាធីនភាពគឺត្រូវបានចាត់ទុកជាជនដែលមានសមត្ថភាពក្នុងការសម្តែងឆន្ទៈ។មានន័យថាជននេះត្រូវចាត់ទុកថាបានដល់នីតិភាព។ ហេតុនេះហើយ អនីតិជនដែលទទួលបានអត្តាធីនភាពអាចបង្កើតកិច្ចសន្យា និងសកម្មភាពឯកតោភាគីដោយមានសុពលភាពតែម្នាក់ឯងបាន ហើយមិនអាចធ្វើការលុបចោលសកម្មភាពទាំងនោះដោយហេតុថាមិនមានការយល់ព្រមពីអ្នកអាណាព្យាបាលបាននោះទេ។ ការទទួលបានអត្តាធីនភាពមាន២ប្រភេទគឺ៖

- ការទទួលបានអត្តាធីនភាពតាមផ្លូវតុលាការ ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ១៦ឆ្នាំទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យតុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អ-នីតិជននោះ[35]។
- ការរៀបអាពាហ៍ពិពាហ៍ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការ[36]។

[32] មាត្រា១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[33] មាត្រា១៩ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[34] មាត្រា១៩ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[35] មាត្រា២១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[36] មាត្រា២១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**សំគាល់៖** ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាពមិនត្រូវរលត់ឡើយ[37]។

### ៣.៤ ជននៅក្រោមអាណាព្យាបាលទូទៅ

ចំពោះជនដែលនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹងនិងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកស្មារតីតុលាការអាចប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅបានតាមពាក្យសុំរបស់សាមីខ្លួន/សហព័ន្ធនិងបុគ្គលផ្សេងទៀតដែលបានកំណត់ក្នុងមាត្រា២៤នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពសម្រាប់វិនិច្ឆ័យនិងយល់ដឹងអំពីលទ្ធផលច្បាប់នៃសកម្មភាពរបស់ខ្លួន គឺសំដៅទៅលើស្ថានភាពដែលខ្វះសមត្ថភាពខាងឆន្ទៈអាចមិនជាប្រចាំ។

ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ១៥ឆ្នាំនៅពេលដែលមានពាក្យសុំគឺមិនត្រូវយកមកអនុវត្តឡើយ។

ជនដែលខ្វះនូវសមត្ថភាពខាងឆន្ទៈ អាចជាអ្នកដែលមានវិបត្តិផ្នែកស្មារតីធ្ងន់ធ្ងរ និងអ្នកជំងឺដែលបាត់បង់ការចងចាំជាដើម។ បុគ្គលដែលត្រូវបានប្រកាសអំពីការចាប់ផ្តើមអាណាព្យាបាលទូទៅ ហៅថាជននៅក្រោមអាណាព្យាបាលទូទៅ ហើយតុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅដើម្បីថែរក្សាជននៅក្រោមអាណាព្យាបាលនោះ [38] ។ អ្នកអាណាព្យាបាលទូទៅ គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ និងមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវធ្វើជាអ្នកតំណាងឲ្យជននោះចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិដែលខ្លួនគ្រប់គ្រង [39] ។សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅអាចលុបចោលបាន[40]។ ទោះបីជាមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏ជននៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពដែលមានសុពលភាពតែម្នាក់ឯងបានទេសូម្បីតែធ្វើកិច្ចសន្យាក៏ដោយក៏កិច្ចសន្យានោះអាចលុបចោលបានដែរ។ ដោយសារតែជននៅក្រោមអាណាព្យាបាលទូទៅស្ថិតក្នុងស្ថានភាពជានិរន្តរ៍គ្មានសមត្ថភាពខាងឆន្ទៈ។ប៉ុន្តែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើម្នាក់ឯងបាន[41]។

---

[37] មាត្រា២១ វាក្យខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[38] មើលមាត្រា២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[39] មើលមាត្រា១១១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[40] មើលមាត្រា២៦ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[41] មើលមាត្រា២៦ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ៣.៥ ជននៅក្រោមហិតូបត្ថម្ភ

ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹងនិងវិនិច្ឆ័យអំពើលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី តុលាការអាចប្រកាសចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ន្ធ និងជនដែលបានកំណត់ផ្សេងទៀត[42]។ សមត្ថភាពតិចតួចពេក គឺសំដៅថាមានសមត្ថភាពខាងឆន្ទៈដែរ តែសមត្ថភាពវិនិច្ឆ័យដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិគឺទាបខ្លាំងជាងធម្មតា។ ជនដែលត្រូវបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភត្រូវបានគេហៅថាជននៅក្រោមហិតូបត្ថម្ភហើយតុលាការជ្រើសរើសហិតូបត្ថម្ភកៈដើម្បីថែរក្សាជននោះនៅក្រោមហិតូបត្ថម្ភ [43] ។ ជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើសកម្មភាពគតិយុត្តសំខាន់ៗដូចដែលបានបញ្ញត្តិក្នុងមាត្រា៣០តែម្នាក់ឯងបានទេដោយមិនបានទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ។ ចំពោះសកម្មភាពគតិយុត្តសំខាន់ៗដែលបានបញ្ញត្តក្នុងមាត្រា៣០ សកម្មភាពនោះអាចលុបចោលបាន។

ទោះបីជាសកម្មភាពដែលបានបញ្ញត្តិក្នុងមាត្រា៣០ក៏ដោយ ក៏មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈនោះទេចំពោះសកម្មភាពទាក់ទងនឹងជីវភាពប្រចាំថ្ងៃ។ហិតូបត្ថម្ភកៈអាចផ្តល់ការយល់ព្រមទៅជននៅក្រោមហិតូបត្ថម្ភចំពោះសកម្មភាពដែលមានបញ្ញត្តិមាត្រា៣០ប៉ុន្តែមិនមានសិទ្ធិតំណាងឲ្យសាមីខ្លួនទេដែលខុសពីអ្នកមានអំណាចមេបានិងអ្នកអាណាព្យាបាលទូទៅ។មានន័យថាហិតូបត្ថម្ភកៈមិនអាចចុះកិច្ចសន្យាក្នុងនាមជាអ្នកតំណាងឲ្យជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភបានទេ។

## ៤.កម្មវត្ថុ

ក្រៅពីការព្រមព្រៀងនិងសមត្ថភាពដែលជាលក្ខណគ្រឹះក្នុងការបង្កើតកិច្ចសន្យា កម្មវត្ថុក៏ជាធាតុសារវន្តមួយផងដែរក្នុងចំណោមលក្ខខណ្ឌគ្រឹះដែលធ្វើកិច្ចសន្យាអាចបង្កើតឡើងបាន។ កម្មវត្ថុត្រូវបានកំណត់ជាលក្ខខណ្ឌសមស្របតម្រូវសម្រាប់សមត្ថភាពក្នុងការបង្កើតកិច្ចសន្យា។ ទស្សនៈនីតិវិទូជាច្រើនបានផ្តល់និយមន័យកម្មវត្ថុនៃកិច្ចសន្យាខុសៗគ្នា។ ទ្រឹស្តីទី១ផ្តល់និយមន័យថាកម្មវត្ថុនៃកិច្ចសន្យាគឺជាកម្មវត្ថុនៃកាតព្វកិច្ចដែលជាតាវកាលិកនិងកម្មវត្ថុនៃតាវកាលិកជាវត្ថុដែលជាប់និងតាវកាលិកនោះ។ផ្ទុយទៅវិញទ្រឹស្តីទី២បានផ្តល់និយមន័យកម្មវត្ថុនៃកិច្ចសន្យា សំដៅទៅកាតព្វកិច្ចគតិយុត្តដែលស្វែងរកដែលចងដោយភាគី[44]។

[42] មើលមាត្រា២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[43] មើលមាត្រា២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[44] មើលសៀវភៅមេរៀន នីតិកាតព្វកិច្ចកិច្ចសន្យា ទំព័រ២៣ បោះពុម្ពឆ្នាំ២០១៧ របស់លោកសាស្ត្រចារ្យ ញឹក វុទ្ធី

### ៤.១ កម្មវត្ថុស្របច្បាប់

កម្មវត្ថុនៃកិច្ចសន្យាដែលស្របច្បាប់មិនប៉ះពាល់ដល់ទំនៀមទំលាប់ដ៏ល្អប្រពៃនិងរបៀបរៀបរយនៃសាធារណៈហើយកម្មវត្ថុនៃកិច្ចសន្យាគឺស្ថិតនៅក្នុងច្បាប់ពាណិជ្ជកម្ម។ កម្មវត្ថុកិច្ចសន្យា ឬ កម្មវត្ថុនៃកាតព្វកិច្ចនេះអាចជាវត្ថុឬ ជាអំពើរបស់ភាគីដែលសន្យាថានឹងប្រតិបត្តិ។ដូចនេះបើយោងតាមអត្ថន័យខាងលើយើងអាចសន្និតកំណត់នូវកម្មវត្ថុមិនស្របច្បាប់គឺផ្ទុយនឹងទំនៀមទំលាប់ដ៏ល្អប្រពៃ និងរបៀបរៀបរយនៃសាធារណៈ ហើយកម្មវត្ថុនៃកិច្ចសន្យាគឺស្ថិតនៅក្រៅពាណិជ្ជកម្មដែល៖

- វត្ថុ : គឺរាល់ទ្រព្យសម្បត្តិទាំងឡាយដែលជាកម្មសិទ្ធិរបស់រដ្ឋ។ល។
- អំពើរបស់ភាគី : ដែលសន្យាថានឹងប្រព្រឹត្តអំពើអ្វីមួយដែលច្បាប់ហាមប្រាម។ល។

  ក្រៅពីវត្ថុដែលច្បាប់ហាមឃាត់ដូចជាគ្រឿងញៀន អាវុធជាដើម ដែលមិនអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាសរីរាង្គរបស់មនុស្សក៏មិនមែនជាកម្មវត្ថុនៃការជួញដូរដែលលើកលែងតែជាកិច្ចសន្យាធ្វើជាអំណោយដោយស្ម័គ្រចិត្តរបស់ភាគីឬក្នុងនាមជាមនុស្សធម៌ជាដើម។សិទ្ធិរបស់បុគ្គលក៏មិនអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាបានដែរ[45]។

### ៤.២ កម្មវត្ថុអាចធ្វើកើត

កម្មវត្ថុនៃកិច្ចសន្យាដែលមនុស្សទូទៅមិនអាចធ្វើកើតបណ្តាលឲ្យកិច្ចសន្យាមោឃៈ។កម្មវត្ថុមិនអាចកើតឡើងអាស្រ័យដោយ៖

ភាពមិនអាចកើតឡើងដោយសារតែលទ្ធភាពនៃការអនុវត្តតាវកាលិកមិនអាចធ្វើកើតដូចជាកិច្ចសន្យាទិញភពអង្គារ។ល។

ភាពមិនអាចកើតឡើងដោយសារតែច្បាប់បានហាមដូចជាកិច្ចសន្យាសាងសង់នៅកន្លែងដែលច្បាប់មិនអនុញ្ញាតឲ្យសាងសង់ កិច្ចសន្យានាំចូលនូវវត្ថុដែលច្បាប់មិនអនុញ្ញាតឲ្យនាំចូល។ល[46]។

ភាពមិនអាចធ្វើកើតដែលធ្វើឲ្យកិច្ចសន្យារងមោឃភាពគឺត្រូវពិនិត្យមើលថាតើភាពមិនអាចធ្វើកើតឬគ្មានលទ្ធភានោះមានលក្ខណៈដាច់ខាតឬមិនដាច់ខាត? បើលក្ខណៈដាច់ខាតកិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈតែបើមានលក្ខណៈមិនដាច់ខាតកិច្ចសន្យានោះនៅមានសុពលភាព។

[45] មើលសៀវភៅមេរៀន នីតិកាតព្វកិច្ចកិច្ចសន្យា ទំព័រ២៣ បោះពុម្ពឆ្នាំ២០១៧ របស់លោកសាស្ត្រចារ្យ ញឹក វុធ្ធី

[46] ទំព័រ២៤ សៀវភៅមេរៀន នីតិកាតព្វកិច្ចកិច្ចសន្យា បោះពុម្ពឆ្នាំ២០១៧ របស់លោកសាស្ត្រចារ្យ ញឹក វុធ្ធី

## ៤.៣ កម្មវត្ថុជាក់លាក់

កម្មវត្ថុជាក់លាក់គឺត្រូវកំណត់ឬអាចកំណត់បានមានន័យថាភាគីក្នុងកិច្ចសន្យាមានលទ្ធភាពវាស់ឬស្ទង់នូវទំហំនៃកាតព្វកិច្ចរបស់ពួកគេ[47]។

ករណីកម្មវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជាប្រាក់៖ បើកិច្ចសន្យាដែលកម្មវត្ថុជាតាវកាលិកស្នាដៃរបស់មនុស្ស តម្លៃនៃការងារមិនចាំបាច់កំណត់មុនក៏បាន ដូចជាមាត្រា៧២ នៃក្រិត្យច្បាប់លេខ៣៨៖កិច្ចសន្យាសហគ្រាសជាកិច្ចសន្យាដែលបុគ្គលម្នាក់ៗទទួលបន្ទុកធ្វើការងារអ្វីមួយឲ្យបុគ្គលម្នាក់ទៀតដោយយកថ្លៃសមស្របនឹងទំហំនៃការងារនោះ។ ក្នុងមាត្រា៧២នេះបញ្ជាក់ថា ថ្លៃការងារអាចនឹងមិនកំណត់ក្នុងកិច្ចសន្យាបាន ព្រោះមាត្រានៃក្រឹត្យច្បាប់នេះបានបញ្ជាក់ថាប្រសិនបើថ្លៃការងារមិនបានកំណត់ក្នុងកិច្ចសន្យាតុលាការត្រូវវិនិច្ឆ័យកំណត់ថ្លៃទៅតាមទំហំនៃកន្លែងធ្វើការនោះ[48]។

ករណីកម្មវត្ថុនៃកិច្ចសន្យាជាវត្ថុគឺត្រូវគូសបញ្ជាក់ថាវត្ថុនោះត្រូវវែចងឲ្យប្រាកដដោយឡែកពីគ្នាតាមប្រភេទ តាមបរិមាណនិងតាមគុណភាព។

ឧទាហរណ៍៖ បើកម្មវត្ថុនៃកិច្ចសន្យាជាស្រូវ ត្រូវកំនត់ប្រភេទស្រូវទំងន់ប៉ុន្មាន។ល។ ពេលខ្លះការកំណត់ពីបរិមាណមិនចាំបាច់ត្រូវជាក់លាក់នៅពេលចុះកិច្ចសន្យាឡើយ គឺអាចកំណត់នៅពេលចុះកិច្ចសន្យាថានឹងផ្តល់វត្ថុក្នុងបរិមាណមិនច្បាស់លាស់ តែអាចកំណត់បាននៅពេលដែលគេប្រតិបត្តិកិច្ចសន្យា។

កម្មវត្ថុជាក់លាក់ក៏បានន័យដែរថាកម្មវត្ថុត្រូវតែមាននៅពេលបច្ចុប្បន្នឬអនាគត។ហេតុនេះបើកិច្ចសន្យាដែលបានចុះនៅពេលដែលវត្ថុត្រូវបានអន្តរាយហើយធ្វើកិច្ចសន្យានោះគ្មានសុពលភាពព្រោះវាគ្មានកម្មវត្ថុជាក់លាក់។ តែបើវត្ថុត្រូវអន្តរាយបន្ទាប់ពីការចុះកិច្ចសន្យា កិច្ចសន្យានោះមានសុពលភាពតែមានបញ្ហាចោទឡើងទៅលើអ្នកដែលត្រូវទទួលខុសត្រូវ។

គេបានធ្វើការបែងចែករវាងកម្មវត្ថុនៃកិច្ចសន្យាជាទ្រព្យដែលមិនអាចជំនួសបាននិងកម្មវត្ថុនៃកិច្ចសន្យាដែលជាទ្រព្យជំនួសបាន។

ទ្រព្យដែលមិនអាចជំនួស៖ ទ្រព្យនេះមានតែមួយ ដូចជារូបចំលាក់បុរាណជាដើម។ ការបាត់បង់ទ្រព្យដែលមិនអាចជំនួសបានគ្មានអ្វីមកជំនួសបានឡើយ ហេតុនេះកិច្ចសន្យាមិនអាចកើតរួចឡើយ។

ទ្រព្យដែលអាចជំនួសបាន៖ ទ្រព្យដែលគេអាចយកមកជំនួសគ្នាបាន ដូចជាទូរស័ព្ទថ្មីមួយគ្រឿងម៉ាកអាយហ្វូន ជាដើម។ បើកម្មវត្ថុនៃកិច្ចសន្យាត្រូវខូចខាត អ្នកលក់មានលទ្ធភាពរកវត្ថុថ្មីដូចគ្នាទាំងស្រុងមកជំនួសដើម្បី

[47] ទំព័រ២៣ សៀវភៅមេរៀន នីតិកាតព្វកិច្ចកិច្ចសន្យា បោះពុម្ពឆ្នាំ២០១៧ របស់លោកសាស្ត្រាចារ្យ ញ៉ឹក វុទ្ធី
[48] ទំព័រ២៤ សៀវភៅមេរៀន នីតិកាតព្វកិច្ចកិច្ចសន្យា បោះពុម្ពឆ្នាំ២០១៧ របស់លោកសាស្ត្រាចារ្យ ញ៉ឹក វុទ្ធី

បំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះអ្នកទិញបានដែរ ហេតុនេះការបាត់បង់វត្ថុគ្មានឧបសគ្គដល់ការកកើតកិច្ចសន្យាឡើយ។

# ជំពូកទី ៣

## ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ

# ជំពូកទី៣

# ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ

## ១.និយមន័យះ

ការខ្ចីបរិភោគគឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថាអ្នកខ្ចីមានករណីកិច្ចប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងៗទៀតក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចីហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឲ្យអ្នកឲ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាពនិងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ[49]។

ចំណែកក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ មាត្រា១២០៦បានចែងមិនសូវទូលាយដូចក្រមបច្ចុប្បន្នទេគេបានឲ្យនិយមន័យការខ្ចីបរិភោគវត្ថុថានាកាលវត្ថុដែលខ្ចីជារបស់ដែលគេបរិភោគបាន អ្នកដែលខ្ចីរបស់គេត្រូវឡើងជាម្ចាស់នៃវត្ថុខ្ចីនោះ អ្នកខ្ចីអាចប្រើប្រាស់នូវវត្ថុនោះតាមទំនើងចិត្តបាន អ្នកនោះត្រូវរកវត្ថុដែលមានធុនដូចគ្នា មានគុណភាពនិងមានចំនួនស្មើគ្នាសងគេវិញតែប៉ុណ្ណោះ។ មួយវិញទៀតពាក់ព័ន្ធជាមួយនឹងការខ្ចីបរិភោគដែលកម្មវត្ថុជាសាច់ប្រាក់វិញនៅក្នុងក្រមរដ្ឋប្បវេណីចាស់បានហៅថាជាការជួលទុន ឬចងការវិញ។

កិច្ចសន្យាខ្ចីបរិភោគត្រូវបានបែងចែកជាពីរប្រភេទគឺះ

- កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់
- កិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់

## ២. ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

យើងបានដឹងមកហើយថា ការបង្កើតកិច្ចសន្យាគឺត្រូវមានសំណើនិងស្វីការ។ ហើយកិច្ចសន្យាមានអានុភាពគឺតម្រូវឲ្យសំណើនិងស្វីការត្រូវគ្នា។ សំណើសំដៅដល់ការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ រីឯស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើរយល់ព្រមចំពោះសំណើនោះ។ កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឲ្យខ្ចី និងអ្នកខ្ចីតែប៉ុណ្ណោះ[50]។

[49]មាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[50] មាត្រា ៥៧៩ នៃកិច្ចសន្យាខ្ចីបរិភោគ

ជាគោលការណ៍សេរីភាពក្នុងកិច្ចសន្យាភាគីអាចកំណត់ថា អានុភាពនៃកិច្ចសន្យានឹងកើតឡើងនៅពេលដែលធ្វើលិខិតកិច្ចសន្យាជាលាយល័ក្ខអក្សរ ឬ នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះបាន[51]។

## ៣. ការរំលាយកិច្ចសន្យា

ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ការបំពានយ៉ាងធ្ងន់ធ្ងរ សំដៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបានដោយសារការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ភាគីដែលបំពានមិនអាចរារាំងការរំលាយកិច្ចសន្យា ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ។

ការព្រមព្រៀងខ្ចីបរិភោគមិនយកការប្រាក់និងមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ ភាគីនៃកិច្ចសន្យាអាចដកកិច្ចសន្យានៅពេលណាក៏បាន ប្រសិនបើអ្នកឲ្យខ្ចីមិនទាន់ប្រគល់កម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគនោះទេ[52]។

នៅពេលបានធ្វើកិច្ចសន្យាខ្ចីបរិភោគ អ្នកឲ្យខ្ចីមានករណីយកិច្ចប្រគល់នូវវត្ថុដែលជាកម្មវត្ថុនោះ។ ក៏ប៉ុន្តែក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីបានត្រូវចុះអន់ថយ ក្រោយពេលធ្វើកិច្ចសន្យា រហូតដល់ពេលប្រគល់នោះ ប្រសិនបើអ្នកឲ្យខ្ចីនៅតែមានករណីយកិច្ចប្រគល់នេះ នោះនឹងបង្កើតឲ្យមានលទ្ធផលអសមភាពមួយ ហេតុនេះហើយ ក្រមបានចែងឲ្យអ្នកខ្ចីអាចរំលាយកិច្ចសន្យាបាន បើមានមូលហេតុវិបត្តិឥណទាន។

ក្នុងករណីដែលស្ថានភាពឥណទានរបស់កូនបំណុលបានចុះអន់ថយមុនពេលធ្វើកិច្ចសន្យា តែអ្នកឲ្យខ្ចីមិនបានដឹងមុននឹងធ្វើកិច្ចសន្យា ករណីនេះមិនអាចអនុវត្តបានឡើយ ប៉ុន្តែអ្នកឲ្យខ្ចីមានលទ្ធភាពក្នុងការទទួលការការពារ តាមបញ្ញត្តិស្តីពីការឆបោក ការភាន់ច្រឡំ ជាអាទិ៍។ ចំពោះការចុះអន់ថយនៃស្ថានភាពឥណទានក្រោយការប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ករណីនេះមិនត្រូវបានអនុវត្តទេ គឺត្រូវចាត់ចែងតាមគោលការណ៍ផ្លាស់ប្តូរស្ថានភាព ឬគោលការណ៍ទូទៅផ្សេងទៀត។

ឧបសន្យានៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគជាការព្រមព្រៀងប្រគល់និងទទួលកម្មវត្ថុជំនួសផ្សេងៗដោយអ្នកមានកាតព្វកិច្ចប្រគល់ និងម្ចាស់បំណុលដែលនឹងផ្លាស់ប្តូរកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគចាស់។ ប្រាតិភោគនៃកិច្ចសន្យាចាស់នឹងក្លាយជាប្រាតិភោគនៃកិច្ចសន្យាថ្មី[53]។

ឧទាហរណ៍៖ ក្នុងករណីដែលអ្នកទិញមិនអាចបង់ថ្លៃលក់ ១ម៉ឺនដុល្លា បានទេ ហើយអ្នកទាំងពីរបានព្រមព្រៀងថា អ្នកលក់ឲ្យអ្នកទិញខ្ចីប្រាក់ ១ម៉ឺនដុល្លា តាមការពិត អ្នកលក់មិនបានឲ្យអ្នកទិញខ្ចី ១ម៉ឺនដុល្លា ទេ ក៏

[51] មើលសេចក្តីកំណត់នីមួយៗនៃក្រមរដ្ឋប្បវេណី ភាគីទី៣ គន្ថីទី៥ មាត្រា ៥៧៩

[52] មើលមាត្រា ៥៨០ នៃក្រមរដ្ឋប្បវេណី ២០០៧

[53] មើលមាត្រា ៥៨២ នៃក្រមរដ្ឋប្បវេណី ២០០៧

ប៉ុន្តែទំនាក់ទំនងនៃកិច្ចសន្យាខ្ចីបរិភោគត្រូវបានបង្កើតឡើង រវាងអ្នកលក់ និងអ្នកទិញ។ ពីព្រោះករណីនេះមិនខុសពីករណីដែលអ្នកលក់ឲ្យអ្នកទិញខ្ចី ១ ម៉ឺនដុល្លា ហើយអ្នកទិញយកលុយនោះទៅបង់ថ្លៃលក់ឲ្យអ្នកលក់វិញ។ ក្នុងករណីនេះ ប្រសិនបើមានឲ្យអ្នកទិញខ្ចី ១ ម៉ឺនដុល្លា ហើយអ្នកទិញយកលុយនោះទៅបង់ថ្លៃលក់ឲ្យអ្នកលក់វិញ។ ក្នុងករណីនេះ ប្រសិនបើមានការធានា ឬ សិទ្ធិហ៊ីប៉ូតែក ដើម្បីធ្វើជាប្រាតិភោគសម្រាប់សិទ្ធិលើបំណុលដែលជាតម្លៃលក់ទិញ ក្រោយមកប្រាតិភោគទាំងនេះនឹងក្លាយជាប្រាតិភោគដែលធានាកាតព្វកិច្ចនៃឧបសន្យាខ្ចីបរិភោគ លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនោះ។

## ៤. ការខ្ចីបរិភោគដោយគ្មានការប្រាក់

កិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។ យើងអាចចែងថា កិច្ចសន្យានេះជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការប្រគល់វត្ថុ ឬដោយបំពេញទម្រង់ណាមួយជាកំណត់បានដោយសារតែលក្ខណៈពិសេសនៃកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។ ក៏ប៉ុន្តែ កិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់ដែលធ្វើឡើងដោយការព្រមព្រៀងដោយផ្ទាល់មាត់ ត្រូវបានប្រើប្រាស់យ៉ាងទូលាយក្នុងជីវភាពប្រចាំថ្ងៃដូចជាការខ្ចីលុយទៅវិញទៅមករវាងមិត្តភក្តិជាដើម។ ហេតុនេះហើយមិនចាំបាច់បដិសេធទាំងស្រុងនូវអានុភាពនោះទេ គ្រាន់តែបន្ថយអានុភាពចងនៃកិច្ចសន្យាបែបនេះគ្រប់គ្រាន់ហើយ។ហេតុនេះហើយ ប្រសិនបើបានធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ អ្នកឲ្យខ្ចីមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុតាមកិច្ចសន្យា ក៏ប៉ុន្តែ ក្នុងករណីដែលកិច្ចសន្យាដែលមិនយកការប្រាក់ត្រូវធ្វើឡើងដោយផ្ទាល់មាត់ ប្រសិនបើអ្នកឲ្យខ្ចីមិនទាន់ប្រគល់លុយខ្ចីជាក់លាក់នៅឡើយទេ អ្នកឲ្យខ្ចីអាចបញ្ឈប់ការឲ្យខ្ចីលុយនោះបានដែរ ដោយមិនចាំបាច់មានមូលហេតុច្បាស់លាស់ទេ[54]។

## ៥. ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

ការប្រាក់សំដៅទៅលើចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលត្រូវបានផ្តល់ទៅឲ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុដែលត្រូវបានប្រគល់ឲ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬ វត្ថុដែលបានខ្ចីមកគុណនឹងអត្រាដែលត្រូវបានកំណត់[55]។ វត្ថុដែលផ្តល់ឲ្យអ្នកខ្ចីហៅថាប្រាក់ដើម ចំណែកការប្រាក់ជាផលស៊ីវិល។

កិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ គឺអ្នកឲ្យខ្ចីត្រូវមានករណីយកិច្ចប្រគល់វត្ថុឲ្យទៅអ្នកខ្ចីហើយវត្ថុដែលប្រគល់នោះត្រូវតែជាវត្ថុដែលគ្មានវិការៈ (វត្ថុដែលមានសភាពល្អធម្មតា)។ ដោយឡែកប្រសិនបើវត្ថុអ្នក

[54] មើលសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី គន្ថីទី៥ មាត្រា៥៨០ ទំព័រ ៤៣

[55] មាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ឲ្យខ្ចីមានវិការៈហើយបានប្រគល់ទៅឲ្យអ្នកខ្ចី ហើយអ្នកខ្ចីពុំបានដឹងអំពីនៃវិការៈនោះ អ្នកខ្ចីអាចទាមទារឲ្យអ្នកឲ្យខ្ចីប្តូរមកវិញនូវវត្ថុដែលគ្មានវិការៈមកឲ្យខ្លួនបាន។ លើសពីនេះអាចទាមទារសំណងខូចខាតបន្ថែមទៀតផង។

ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចយកកម្មវត្ថុនៃការសងការប្រាក់ មកបង្កើតជាសិទ្ធិលើបំណុលតាមការព្រមព្រៀងបាន។ ប៉ុន្តែ ចំពោះការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃកាប្រាក់ ប្រសិនបើពុំបានធ្វើកិច្ចសន្យាលាយល័ក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចីទេ ពុំមានអានុភាពឡើយ។

## ៦. អត្រាការប្រាក់

### ៦.១ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

ប្រាក់ ឬ វត្ថុជំនួសផ្សេងទៀតដែលបង់ដោយយកអត្រាកំណត់មួយ តាមសមាមាត្រនៃចំនួនប្រាក់ដើម ឬ វត្ថុដើម និងអំឡុងពេលនៃប្រើប្រាស់ ក្នុងនាមជាតម្លៃថ្នូរនៃការប្រើប្រាស់ដើម ឬ វត្ថុដើមដោយអ្នកខ្ចី (តម្លៃថ្នូរចំពោះការដែលអ្នកឲ្យខ្ចីមិនអាចប្រើវត្ថុដែលជាកម្មវត្ថុរបស់ខ្លួន ក្នុងអំឡុងពេលកំណត់មួយ) ត្រូវហៅថាជាការប្រាក់។

អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ សំដៅទៅលើអត្រាការប្រាក់ដែលមានចែងកំណត់ទុកជាមុននៅក្នុងច្បាប់។ ក្នុងករណីដែលភាគី មិនបានព្រមព្រៀងគ្នា អំពីអត្រាការប្រាក់នៅក្នុងកិច្ចសន្យាទេគឺ គេត្រូវយកអត្រាការប្រាក់ដែលបានកំណត់ដោយច្បាប់ យកមកអនុវត្តនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់។ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់នេះគឺ៥% នៅក្នុង១ឆ្នាំ[56]។

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាឆ្នាំ១៩៩៦ បានកំណត់អំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជាមានតួនាទីកំណត់អត្រាការប្រាក់[57]។ ដូចនេះអត្រាការប្រាក់ដែលត្រូវយកមកអនុវត្តនៅក្នុងវិស័យធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានកំណត់ដោយបទបញ្ញត្តិពិសេសរបស់ធនាគារជាតិ។

### ៦.២ អត្រាការប្រាក់ក្នុងកិច្ចសន្យា

ការកំណត់អត្រាការប្រាក់ដោយច្បាប់វាអាចផ្តល់ផលប៉ះពាល់ខ្លាំងទៅលើការរីកចំរើនផ្នែកសេដ្ឋកិច្ច ដោយសារកត្តានេះហើយទើបក្រមរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជាក៏បានអនុញ្ញាតឲ្យគូភាគីអាចកំណត់អត្រាការប្រាក់តាមការព្រមព្រៀងរបស់គូភាគីបានដោយមិនចាំបាច់ ធ្វើការអនុវត្តតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ (៥%) ព្រោះថានៅក្នុងកិច្ចសន្យាខ្ចីបរិភោគមានហានិភ័យខ្ពស់ណាស់ចំពោះអ្នកឲ្យខ្ចី ដោយមានប្រាក់ ឬ វត្ថុទៅឲ្យគេខ្ចី ហើយទទួលបានការប្រាក់ទាប តែត្រូវប្រឈមមុខនឹងការខាតបង់យ៉ាងខ្លាំងក្នុងការឲ្យប្រាក់ ឬ វត្ថុរបស់ខ្លួនប្រើប្រាស់ដោយសេរី តែអ្វីដែលជាថ្នូរចំពោះការប្រើប្រាស់នេះវាគ្រាន់តែទទួល

[56] មាត្រា ៥៩ ក្រឹត្យច្បាប់លេខ៣៨ និង មាត្រា ៣១៨នៃក្រមរដ្ឋប្បវេណី ២០០៧

[57] មាត្រា ៧ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឆ្នាំ ១៩៩៦

បានប្រាក់បន្តិចបន្តួច។ ម្យ៉ាងវិញទៀតតើមាននរណាប្រថុយឲ្យប្រាក់ខ្លួនទៅគេខ្ចីនោះបើទទួលបានការប្រាក់ទាប យ៉ាងនេះ។

តាមអត្ថន័យនៃមាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណីបានអនុញ្ញាតឲ្យគូភាគីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អាចធ្វើការព្រមព្រៀងដោយសេរីនៅក្នុងការកំណត់នូវអត្រាការប្រាក់របស់ខ្លួននៅក្នុងកិច្ចសន្យាបាន ទោះបីជាការព្រមព្រៀងនោះ មានការកំណត់នូវអត្រាការប្រាក់ ហួសពីអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ក៏ដោយ ក៏ការព្រមព្រៀងនោះមានអានុភាព តែត្រូវធ្វើជាលាយល័ក្ខអក្សរ។

### ៦.៣ ការកម្រិតការប្រាក់

អត្រាការប្រាក់ដែលបានកំរិតគឺសំដៅទៅលើអត្រាការប្រាក់អតិបរមា ដែលអាចកំណត់បានដោយស្របច្បាប់ ឬ ត្រូវបានកំណត់ឡើងដោយច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងៗដែលមានជាធរមាន ហើយគូភាគីមិនអាចធ្វើការព្រមព្រៀងគ្នាឲ្យលើសការកម្រិតបានឡើយ។

តាមច្បាប់ស្ដីពី ការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ មាត្រា ១៧ អត្រាការប្រាក់ដែលត្រូវបានកម្រិតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី១០% ទៅ៣០%ក្នុង១ឆ្នាំ។ តាមការប្រកាសរបស់ក្រសួងយុត្តិធម៌ស្ដីពីអត្រាការប្រាក់ដែលបានកម្រិតថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ អត្រាការប្រាក់ដែលត្រូវបានកម្រិតគឺ ១៨% នៅក្នុងឆ្នាំ។ យោងតាមប្រកាសការប្រាក់កម្ចីឥណទាន របស់ធនាគារជាតិនៃកម្ពុជា មាត្រា៤ ចែងថាស្ថាប័នមិនត្រូវកំណត់ការប្រាក់លើសពី១៨% ក្នុង១ឆ្នាំនៃការកំណត់សង។

ប្រសិនបើ ភាគីបានកំណត់អត្រាការប្រាក់ លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត កិច្ចសន្យានៃភាគដែលលើសពីការកម្រិតនៃអត្រាការប្រាក់នោះត្រូវទុកជាមោឃៈ រីឯអ្នកខ្ចី មានករណីយកិច្ចសងត្រឹមតែ ចំណែកចំពោះការប្រាក់ដែលត្រូវបានគណនា តាមអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះតែប៉ុណ្ណោះ។ នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតហើយ ត្រូវចាត់ទុកជាភាគដែលលើសពីការកម្រិតនោះជាការកាត់បំណុលទៅលើប្រាក់ដើម[58]។

នៅក្នុងករណីដែល បានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសពីការកម្រិតហើយ តែនៅមានសេសសល់ទៀត អ្នកឲ្យខ្ចីត្រូវសងទៅឲ្យអ្នកខ្ចីដោយភ្ជាប់ជាមួយ នូវប្រាក់សំណងនៃការខូចខាត ដោយគណនាតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឲ្យមានការសេសសល់នៃការសងរហូតដល់ថ្ងៃដែលបានសងនោះ។

[58] មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី

## ៦.៤ ពេលវេលានៃការបង់ការប្រាក់និងការប្រាក់សមាសដែលកំណត់ដោយច្បាប់

### ៦.៤.១ ពេលវេលានៃការបង់ការប្រាក់

បើគ្មានការកំណត់ពិសេសទេ ការប្រាក់ត្រូវបង់នៅរៀងរាល់ពេលដែលពេលវេលា១ឆ្នាំបានកន្លងផុត គិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ[59]។ ហើយនេះមិនមែនជាបញ្ញត្តិដោយបង្ខំដែល មានន័យថាគីភាគីអាចធ្វើការព្រមព្រៀងគ្នាផ្សេងទៀតបាន។ ដោយភាគីអាចអាចព្រមព្រៀងបង់រៀងរាល់ខែ ឬ កន្លះឆ្នាំម្តងជាដើម។ ប្រសិនបើត្រូវសងវត្ថុដែលជាកម្មវត្ថុនោះ នៅមុនពេលដែលពេលវេលា ១ឆ្នាំមិនទាន់បានកន្លងផុត ត្រូវបង់ការប្រាក់នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ[60]។

### ៦.៤.២ ការប្រាក់សមាសដែលកំណត់ដោយច្បាប់

ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី១ឆ្នាំ ឡើងទៅ ហើយទោះបីជាអ្នកឲ្យខ្ចីដាស់តឿនយ៉ាងណាក៏ដោយក៏អ្នកខ្ចីមិនព្រមសងការប្រាក់នោះ អ្នកឲ្យខ្ចីអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន[61]។ ការបូកបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើម ការប្រាក់នឹងត្រូវគិតទៅការប្រាក់ជាបន្តទៀត ដែលនេះគេហៅការប្រាក់សមាស។

ឧទាហរណ៍៖ ការប្រាក់ត្រូវបង់ជារៀងរាល់ខែ តែប្រសិនបើមិនបានបង់ទេ គេនឹងបូកបញ្ចូលទៅក្នុងប្រាក់ដើមដោយស្វ័យប្រវត្តិ ហើយការបូកបញ្ចូលទៅក្នុងប្រាក់ដើមក្នុងរយៈពេលដ៏ខ្លី ជាសារធាតុនឹងធ្វើឲ្យការប្រាក់កើនយ៉ាងលឿន។ ដូចនេះ ប្រសិនជាគ្មានការព្រមព្រៀងពិសេសរវាងភាគីទេ ការប្រាក់ត្រូវសងដោយគិតជាឆ្នាំ ហើយទទួលស្គាល់ឲ្យគិតការប្រាក់សមាស តែក្នុងករណីដែលមានការយឺតយ៉ាវក្នុងការបង់ប្រាក់សម្រាប់អំឡុងពេលចាប់ពីមួយឆ្នាំឡើងទៅ ហើយអ្នកខ្ចីមិនបានបង់ ទោះបីជាត្រូវបានដាស់តឿនក៏ដោយ។ ម្យ៉ាងទៀត ប្រសិនបើមានកិច្ចព្រមព្រៀងពិសេសដោយបូកបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមច្រើនដងក្នុងមួយឆ្នាំ ចំពោះការអនុវត្តមាត្រា ៥៨៥ ត្រូវគិតមើលទំនាក់ទំនងរវាងការប្រាក់សរុបមួយឆ្នាំ និងប្រាក់ដើមនៃឆ្នាំនោះ ហើយសម្រេចថា តើការប្រាក់សរុបនោះលើសការប្រាក់ដែលត្រូវបានកម្រិតក្នុងមាត្រានោះឬទេ។

[59] មាត្រា ៥៨៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[60] មាត្រា ៥៨៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[61] មាត្រា ៥៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

# ៧. អនុវត្តកិច្ចសន្យាខ្ចីបរិភោគ

## ៧.១ ភាតព្វកិច្ចអ្នកឱ្យខ្ចី

### ៧.១.១ ករណីឲ្យខ្ចីវត្ថុដែលជាកម្មវត្ថុ

អ្នកឲ្យខ្ចីមានករណីកិច្ចឲ្យអ្នកខ្ចីប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា។ រីឯ អ្នកខ្ចីអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុ ដោយសេរីបាន ហើយត្រូវទទួលបន្ទុកហានិភ័យ លើការបាត់បង់ ឬ ខូចខាត ចំពោះវត្ថុដែលជាកម្មវត្ថុ ដែលកើតឡើងដោយសារមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឲ្យខ្ចី ក្នុងនាមជាកម្មសិទ្ធិករ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុ[62]។

### ៧.១.២ ការទទួលខុសត្រូវក្នុងការធានារបស់អ្នកខ្ចី

#### ក-ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចីក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឲ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន មានករណីកិច្ចត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ហើយផ្ទេរទៅឲ្យអ្នកខ្ចី ឬ ត្រូវប្តូរជាមួយនឹងវត្ថុដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន។ ប៉ុន្តែ នៅក្រោយពេលដែលអ្នកខ្ចីបានបរិភោគវត្ថុនោះរួចហើយ ពុំអាចទាមទារឲ្យប្រគល់វត្ថុជំនួសបានឡើយ។ ប្រសិនបើអ្នកឲ្យខ្ចី ពុំអាចអនុវត្តកាតព្វកិច្ចខាងលើបានទេ អ្នកខ្ចីអាចរំលាយកិច្ចសន្យាបាន។

ស្របគ្នានេះដែលប្រសិនបើអ្នកខ្ចីទទួលការប្រគល់វត្ថុខ្ចី ដោយពុំបានដឹងថាអ្នកឲ្យខ្ចីនោះគ្មានសិទ្ធិ អ្នកខ្ចីអាចទាមទារឲ្យអ្នកឲ្យខ្ចីសងសំណងនៃការខូចខាតបាន។

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ បញ្ញត្តិទាំងនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតែករណីដែលអ្នកឲ្យខ្ចីបានដឹងថាខ្លួនគ្មានសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុ ហើយបានប្រគល់វត្ថុរបស់អ្នកដទៃនោះដោយពុំបានជូនដំណឹងទៅឲ្យអ្នកខ្ចី។ មានន័យថាអ្នកឲ្យខ្ចីមានបំណងទុច្ចរិត ទើបត្រូវទទួលខុសត្រូវ។

#### ខ-ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឲ្យខ្ចីនូវវត្ថុដែលមានវិការៈ

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ប្រសិនបើមានវិការៈកំបាំងនៅក្នុងវត្ថុដែលអ្នកឲ្យខ្ចីបានប្រគល់ អ្នកខ្ចីដែលទទួលបានការប្រគល់ដោយមិនបានដឹងអំពីវិការៈនោះអាចទាមទារឲ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ និងអាចទាមទារសំណងនៃការខូចខាតបាន។

[62] មាត្រា ៥៨៧ នៃក្រមរដ្ឋប្បវេណី

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ អ្នកខ្ចីដែលទទួលការប្រគល់វត្ថុដែលមានវិការៈ អាចសងតម្លៃនៃវត្ថុដែលមានវិការៈបាន។ ចំពោះករណីដែលអ្នកឲ្យខ្ចីបានដឹងអំពីវិការៈនោះហើយ តែពុំបានជូនដំណឹងទៅឲ្យអ្នកខ្ចី អ្នកខ្ចីក៏អាចទាមទារសំណងនៃការខូចខាតបានដូចគ្នា[63]។

ឧទាហរណ៍៖ ក្នុងកិច្ចសន្យាខ្ចីបរិភោគមួយ អ្នកឲ្យខ្ចីបានប្រគល់គ្រាប់ពូជពោតដែលមានជំងឺទៅឲ្យអ្នកខ្ចី អ្នកខ្ចីដែលបានទទួលស្រូវនោះពុំបានដឹងថាគ្រាប់ពូជពោតនោះមានជំងឺ អ្នកខ្ចីអាចទាមទារឲ្យអ្នកឲ្យខ្ចីប្តូរគ្រាប់ពូជពោតដែលល្អមិនមានជំងឺមកខ្លួនវិញបាន។ ប្រសិនបើគ្រាប់ពូជពោតនោះបានឆ្លងជំងឺទៅកាន់គ្រាប់ពូជរបស់គាត់ក្នុងជង្រុកនោះ គាត់ក៏អាចទាមទារឲ្យអ្នកឲ្យខ្ចីសងសំណងនៃការខូចខាតបាន។

ប្រសិនបើ អ្នកខ្ចីគ្រាប់ពូជពោតដោយគ្មានការប្រាក់ មិនអាចទាមទារឲ្យអ្នកឲ្យខ្ចីប្តូរគ្រាប់ពូជពោតល្អវិញ ឬ តាមទារឲ្យអ្នកឲ្យខ្ចីសងនូវសំណងនៃការខូចខាតបានឡើយ ទោះបីគ្រាប់ពូជនោះមានវិការៈក៏ដោយ។ ក្នុងករណីនេះជាគោលការណ៍អ្នកខ្ចីត្រូវសងនូវគ្រាប់ពូជដែលមានវិការៈដូចគ្នាវិញ ប៉ុន្តែក្នុងប្រតិបត្តិប្រចាំថ្ងៃវាមិនសូវសមស្របទេ ហេតុនេះគេអាចឲ្យអ្នកខ្ចីសងជាប្រាក់ត្រឹមតម្លៃគ្រាប់ពូជដែលមានវិការៈ។ ប៉ុន្តែប្រសិនបើអ្នកឲ្យខ្ចីបានដឹងថាគ្រាប់ពូជពោតនោះមានវិការៈហើយលាក់កំបាំងចំពោះអ្នកខ្ចី អ្នកឲ្យខ្ចីត្រូវសងសំណងនៃការខូចខាតដែលអ្នកខ្ចីបានទទួលរងគ្រោះដោយសារវិការៈនោះ។

## ៧.២ ករណីយកិច្ចរបស់អ្នកខ្ចី

អ្នកខ្ចី មានករណីកិច្ចត្រូវសងទៅឲ្យអ្នកខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង[64]។

### ៧.២.១ករណីយកិច្ចត្រូវសង

#### ក-ពេលវេលានៃការសង

ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង អ្នកឲ្យខ្ចីមិនអាចទាមទារឲ្យសងវត្ថុនោះមុនពេលកំណត់ត្រូវសង តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងកិច្ចសន្យាបានឡើយ។ ប៉ុន្តែមានករណីមួយចំនួនដែលអ្នកឲ្យខ្ចីអាចធ្វើការទាមទារឲ្យសងមុនពេលកំណត់នោះបាន។ ករណីនោះមានដូចជា៖ អ្នកខ្ចីត្រូវបានប្រកាសក្ស័យធន កូនបំណុលបានធ្វើឲ្យខូចខាប្រាតិភោគ កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែមិនបានបំពេញករណីនេះ និងមានហេតុដែលគូភាគីបានព្រមព្រៀងគ្នា បានកើតឡើង[65]។

---

[63] មាត្រា ៥៩០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[64] មាត្រា ៥៩១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[65] មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី

ចំពោះកាតព្វកិច្ចដែលឥតមានកំណត់ពេលវេលាសងវិញ ជាគោលការណ៍ នៅពេលដែលម្ចាស់បំណុលដាស់តឿនពេលដែលត្រូវសងបំណុលមកដល់ (មាត្រា ៣៨៩ ចំណុច គ) ប៉ុន្តែ ប្រសិនបើយកគោលការណ៍នេះមកអនុវត្តចំពោះការខ្ចីបរិភោគ ពេលណាក៏អ្នកខ្ចីត្រូវត្រៀមសងវិញដែរ ហើយការខ្ចីបរិភោគក្លាយទៅជាគ្មានន័យទៅវិញ ហេតុនេះហើយបានជាកថាខណ្ឌទី២ នៃមាត្រា៥៩៤ បានបញ្ញត្តិថា ក្រោយអំឡុងពេលសមរម្យមួយបានកន្លងផុតពីពេលដាស់តឿនសងទើបដល់ពេលត្រូវសង ដែលក្នុងអំឡុងពេលសមរម្យនេះ អ្នកខ្ចីអាចត្រៀមដើម្បីសងបាន[66]។

ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ការសងមុនពេលកំណត់ និងធ្វើឲ្យខូចផលប្រយោជន៍ដលើការទទួលការប្រាក់របស់អ្នកខ្ចី ហេតុនេះហើយបានជាមានចម្ងល់មួយកើតឡើងថា ប្រហែលជាអ្នកខ្ចីគ្មានសេរីភាពក្នុងការបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលទេ ដូចនេះគេបានបញ្ញត្តិថា៖ អ្នកខ្ចីអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលបាន ( អ្នកឲ្យខ្ចីមិនអាចទាមទារឲ្យសងមុនពេលកំណត់បានឡើយ)។ ក្នុងករណីនេះ អ្នកខ្ចីមានករណីយកិច្ចត្រូវសងនូវការខូចខាតរបស់អ្នកឲ្យខ្ចី ដោយស្របតាមកថាខណ្ឌទី២ នៃមាត្រា៣៣០។ ការខូចខាតត្រូវស្ថិតនៅលើការបកស្រាយ។ យើងដឹងហើយ ការប្រាក់គឺជាតម្លៃថ្នូរនៃការប្រើប្រាស់ប្រាក់ដើម ហើយអ្នកឲ្យខ្ចីអាចប្រើប្រាស់នៅប្រាក់ដើមរបស់ខ្លួន បន្ទាប់ពីពេលដែលបានទទួលការសងមុនពេលកំណត់ ហេតុនេះហើយបានជាភាគច្រើនគេបកស្រាយ ការប្រាក់ដែលកើតឡើងពីថ្ងៃសងរហូតដល់ថ្ងៃកំណត់ក្នុងកិច្ចសន្យា មិនមែនជាការខូចខាតទេ។ ដូច្នេះ ការខូចខាតក្នុងន័យនេះគេសំដៅទៅលើសាហ៊ុយផ្សេងៗដែលកើតឡើងដើម្បីទទួលនូវការសងមុនពេលកំណត់នោះ ដែលត្រូវបន្ថែមពីសាហ៊ុយទទួលការសងនៅពេលកំណត់ ដូចជាសាហ៊ុយសំរាប់គណនាប្រាក់សារជាថ្មី សាហ៊ុយលើកិច្ចសន្យាជាដើម។

**ខ-ទីកន្លែងនៃការសង**

ប្រសិនបើពុំមានការព្រមព្រៀងរវាងភាគី អំពីទីកន្លែងនៃការសងទេ អ្នកខ្ចីត្រូវយកវត្ថុដែលជាកម្មវត្ថុនោះទៅសងនៅលំនៅឋានរបស់អ្នកឲ្យខ្ចី[67]។

**គ-ករណីដែលអ្នកខ្ចីមិនអាចសងវត្ថុបាន**

ប្រសិនបើអ្នកខ្ចីមិនអាចសងបានទេ អ្នកខ្ចីមានករណីកិច្ចត្រូវបង់ប្រាក់ដែលសមរម្យនិងតម្លៃនៃវត្ថុដែលជាកម្មវត្ថុ នៅទីកន្លែង និងថ្ងៃដែលត្រូវសង ។ ប្រសិនបើ ពុំមានកំណត់ថ្ងៃ ឬ ទីកន្លែងដែលត្រូវសងទេ ត្រូវចាត់ទុកថាត្រូវបង់ចំនួនប្រាក់ដែលសមរម្យនិងតម្លៃនោះនៅថ្ងៃ និងទីកន្លែងដែលបានធ្វើកិច្ចសន្យា។

[66] មើលសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី មាត្រា៥៩៤

[67] មាត្រា ៥៩៥ នៃក្រមរដ្ឋប្បវេណី ៥៩៤

ឧទាហរណ៍៖ ក្នុងករណីដែលបានធ្វើកិច្ចសន្យាខ្ចីបរិភោគថ្នាំសម្លាប់សត្វល្អិតសម្រាប់កសិកម្មចំនួន ៥០ គីឡូ ហើយក្រោយពីបានប្រគល់វត្ថុដែលជាកម្មវត្ថុនោះ រហូតដល់កាលបរិច្ឆេទដែលត្រូវសងតាមកិច្ចសន្យាវិញ ផលិតកម្មនិងការលក់ថ្នាំសម្លាប់សត្វល្អិតនោះត្រូវបានហាមឃាត់។ ក្នុងករណីនេះ អ្នកខ្ចីមិនអាចសងថ្នាំសម្លាប់សត្វល្អិតដែលមានប្រភេទដូចគ្នាបានទេ ហេតុនេះហើយដោយយោងតាមមាត្រានេះ អ្នកខ្ចីអាចសងជាប្រាក់ដែលស្មើនឹងតម្លៃថ្នាំនោះបាន។

### ៧.២.២ កាតព្វកិច្ចបង់ការប្រាក់

អ្នកខ្ចីត្រូវមានកាតព្វកិច្ចបង់ការប្រាក់ ហើយការបង់ការប្រាក់ត្រូវអនុលោមទៅតាមអត្រាការប្រាក់ដែលបានកំណត់ដោយច្បាប់ និងអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ទោះបីជាតម្លៃនៃរូបិយវត្ថុ ឬ តម្លៃនៃវត្ថុមានការប្រែប្រួលនៅមុនពេលសងក៏ដោយ លើកលែងតែ ក្នុងករណីដែលមានការព្រមព្រៀងពិសេស អ្នកខ្ចីត្រូវសងនូវចំនួនទឹកប្រាក់ ដូចគ្នា នឹងចំនួនទឹកប្រាក់ដែលទទួលបានពីការប្រគល់[៦៨]។

**ឧទាហរណ៍៖** ការខ្ចីលុយចំនួន ៥ពាន់ដុល្លាដែលត្រូវដល់ពេលសងវិញ ទោះបីជាតម្លៃនៃរូបិយវត្ថុបានធ្លាក់ចុះក៏ដោយ អ្នកខ្ចីគ្រាន់តែសងជាទឹកប្រាក់ចំនួណ ៥ពាន់ដុល្លាគឺគ្រប់គ្រាន់ហើយ។ បើសិនចង់ទទួលបានតម្លៃសារធាតុ ចាំបាច់ត្រូវធ្វើការសន្យាពិសេស ដោយគិតប្រាក់ដែលសងទៅតាមការផ្លាស់ប្តូរនៃតម្លៃរូបិវត្ថុ តម្លៃមាស តម្លៃទំនិញ ជាដើម។ ក្នុងករណីដែលបានទទួលលទ្ធផលមួយដែលមានអសមភាពយ៉ាងខ្លាំងដោយសារតែគោរពនូវគោលការណ៍ខាងលើ គេអាចកែប្រែទៅតាមគោលការណ៍ស្ថានភាពបាន។

## ៨. បញ្ហាទូទៅដែលកើតមានក្នុងកិច្ចសន្យាខ្ចីបរិភោគ

នៅក្នុងសង្គមប្រតិបត្តិការរាល់ថ្ងៃដែលពេលខ្លះគេឃើញមានរឿងរដ្ឋប្បវេណីបានក្លាយទៅជារឿងព្រហ្មទណ្ឌ។ជាក់ស្តែងដូចក្នុងរឿងកិច្ចសន្យាខ្ចីបរិភោគនៅពេលដែលអ្នកខ្ចីមិនបានបំពេញកាតព្វកិច្ចសងប្រាក់ទៅឲ្យអ្នកឲ្យខ្ចី គេឃើញមានកងប្រដាប់អាវុធ សមត្ថកិច្ចមូលដ្ឋានជាដើម បានចុះទៅចាប់អ្នកខ្ចីដល់ទីតាំងដែលគេរស់នៅ តើសកម្មភាពបែបនេះត្រឹមត្រូវឬទេ តើរឿងរដ្ឋប្បវេណីអាចក្លាយជារឿងព្រហ្មទណ្ឌដែលឬទេ? ប្រសិនបើជារឿងដែលទាក់ទងនឹងត្រឹមការខ្ចីចងការប្រាក់ទេ មិនមែនជារឿងព្រហ្មទណ្ឌទេ ទាំងច្បាប់ជាតិ ទាំងច្បាប់អន្តរជាតិ។ ជាគោលការណ៍ប្រសិនបើជារឿងរដ្ឋប្បវេណីគេត្រូវដោះស្រាយតាមនីតិវិធីរដ្ឋប្បវេណី។ មិនអាចចាប់ចងដូចរឿងព្រហ្មទណ្ឌបាននោះទេ។ សំណួរសួរថា ប្រសិនបើមានការធ្វើបែបនេះមែនតើវាមានបញ្ហាទេ វាសមនឹងគោលការណ៍ច្បាប់ដែរឬទេ? ឧទាហរណ៍ថាខ្ចីលុយមួយខែចំនួន១០ម៉ឺនដុល្លា រហូតដល់ថ្ងៃកំណត់អ្នកខ្ចីមិនបានសងទៅអ្នកឲ្យខ្ចី។ នៅពេលដែលមកដាស់តឿននិងទាមទារអ្នកខ្ចីតែងតែនិយាយថា ចាំអាទិត្យក្រោយ ចាំ

[៦៨] មើលមាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណី

អាទិត្យក្រោយមួយទៀត ខែក្រោយជាដើម ។ ដោយសារតែការសន្យានេះច្រើនដងពេក ហើយអ្នកខ្ចីនៅតែមិនសង។ អ្នកឲ្យខ្ចីបានចោទអ្នកខ្ចីថាបោកប្រាស់គាត់។ ដូចនេះគាត់បានប្ដឹងអំពីបទឆបោក ឬ ជាបទរំលោភទំនុកចិត្ត ព្រោះកិច្ចសន្យាបានកើតឡើងហើយសន្យាថានឹងសងតែនៅតែមិនសង។ ពិតណាស់ក្នុងសង្គមជាក់ស្ដែងគេតែងឃើញមានបទល្មើសពីរហ្នឹង គឺបទល្មើសឆបោកនិងបទល្មើសរំលោភលើទំនុកចិត្ត ដែលកើតចេញពីការមិនអនុវត្តកិច្ចសន្យា។ ប៉ុន្តែជាគោលការណ៍ក្នុងរឿងព្រហ្មទណ្ឌគេបកស្រាយតឹងរ៉ឹងណាស់ គេបានផ្ដល់សេរីភាពច្រើនជាងការកំរិតសេរីភាព។ គេមិនងាយធ្វើរឿងរដ្ឋប្បវេណីឲ្យក្លាយទៅជារឿងព្រហ្មទណ្ឌទេ។ ប៉ុន្តែតើវាអាចកើតមានដែរទេ ? ពិតណាស់វាអាចកើតមានដែរ ប៉ុន្តែយើងត្រូវពិនិត្យឲ្យច្បាស់ទៅលើធាតុផ្សំនៃបទល្មើស។ ការឆបោក គឺជាអំពោះបន្លំចំពោញរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬ ដោយប្រើឧបាយកលទុច្ចរិត ហើយដូចនេះបានទទួលពីបុគ្គលនេះដែលនាំឲ្យខូចប្រយោជន៍របស់បុគ្គលនេះ [69] ។ អំពើរំលោភទំនុកចិត្តគឺជាអំពើគៃបំបាត់មូលនិធិតម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយនាំឲ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ដែលគេបានប្រគល់ឲ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិនោះទៅធ្វើការប្រើប្រាស់ជាកំណត់ [70] ។ ដូចនេះ យើងឃើញហើយថា បទល្មើសឆបោកវាទាមទារឲ្យមានកលល្បិច ការប្រាប់ព័ត៌មានមិនពិត ការក្លែងឋានៈជាមុនដើម្បីទៅខ្ចីគេ មានន័យថាមានល្បិចឆបោករួចហើយមុនពេលទៅខ្ចីគេ នេះបង្ហាញពីចេតនាទុច្ចរិតរបស់អ្នកខ្ចី។ ចំណែកឯបទល្មើសរំលោភលើទំនុកចិត្តក៏ដូចគ្នាដែរ មានន័យថាការដែលគាត់ខ្ចីហើយមានចេតនាទុច្ចរិត ការអត់លុយសងមិនមែនជាចេតនាទុច្ចរិតឡើយ។ អ្វីទៅជាចេតនាទុច្ចរិត? ឧទាហរណ៍ ខ្ចីឡាន ក្រោយពីបានខ្ចីឡានរួចដល់ពេលកំណត់គាត់មិនបានសងទេ តែបែជាយកទៅលក់ ដូចនេះហើយការបំភ្លែងកម្មសិទ្ធិរបស់អ្នកដទៃបែបនេះវាបានចាត់ចូលជាបទល្មើសហើយ គឺរំលោភលើសេចក្ដីទុកចិត្តនេះឯង។ នេះអាចចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងរឿងការខ្ចីបរិភោគនេះជារឿងស៊ីវិលសុទ្ធសាធ មិនមែនជារឿងព្រហ្មទណ្ឌទេ ប្រសិនបើមានការចាត់តាមផ្លូវច្បាប់ព្រហ្មទណ្ឌវាមិនសូវត្រឹមត្រូវទេ ព្រោះថាការមិនមានលុយសងមិនមែនជាចេតនាទុច្ចរិតទេ ហើយអ្នកខ្ចីពិតជាអត់លុយសងមែន។ តាមនីតិវិធីផ្លូវច្បាប់គេផ្ដល់សិទ្ធិទាមទាររបស់ខ្លួនតាមរយៈការប្ដឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីទាមទារឲ្យសងប្រាក់ ប្រសិនបើរកឃើញថាគេមានទ្រព្យដូចជា ផ្ទះ ឡាន វត្ថុមានតម្លៃផ្សេងៗ គេអាចអនុវត្តដោយបង្ខំលក់ឡៃឡុងនូវវត្ថុទាំងនោះដើម្បីយកលុយមកសងទូទាត់បំណុល ដូចនេះវាយុត្តិធម៌ណាស់សំរាប់គូភាគី។ ប៉ុន្តែការអនុវត្តជាក់ស្ដែងបើសិនប្រើរឿងរដ្ឋប្បវេណីវាទាមទារពេលវេលាយូរ ដូចនេះហើយដើម្បីជារបៀបនៃការដាក់សម្ពាធគេធ្វើរឿងព្រហ្ម

[69] មើលមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ

[70] មើលមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ

ទណ្ឌតែម្តង។ ប៉ុន្តែវាជារឿងមិនគួរគប្បីទេ ព្រោះថាយើងអនុវត្តតែសិទ្ធិទាមទារបំណុលយើងបានហើយ ចៀសវាងព្យាយាមធ្វើរឿងនេះឲ្យក្លាយជារឿងព្រហ្មទណ្ឌ ព្រោះរឿងព្រហ្មទណ្ឌទាក់ទងនឹងការជាប់គុក ការដកសិទ្ធិសេរីភាព។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការខ្ចីបរិភោគគឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថាអ្នកខ្ចីមានករណីកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងៗទៀត ក្នុងអំឡុងពេលដែលបានកំណត់ឱ្យទៅភាគីម្ខាងទៀតហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឲ្យអ្នកឲ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាពនិងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ។ ពាក្យថាខ្ចីបរិភោគមិនសំដៅតែការខ្ចីវត្ថុដែលបរិភោគបាននោះទេ ប៉ុន្តែសំដៅដល់វត្ថុទាំងឡាយណាដែលបាត់បង់ក្រោយប្រើប្រាស់។ ក្នុងន័យនេះ ប្រាក់ដែលអ្នកឲ្យខ្ចីបានឲ្យទៅដល់អ្នកខ្ចីនឹងបាត់បង់ក្រោយពេលឲ្យខ្ចីនោះ ថ្វីត្បិតតែតម្លៃរបស់វានៅតែរក្សាដដែលក៏ដោយ។ ជាក់ស្តែងអ្នកខ្ចីនឹងសងចំនួនទឹកប្រាក់ដែលខ្លួនជំពាក់នោះមកឲ្យអ្នកខ្ចីវិញបន្ទាប់ពីរយៈពេលមួយ ប៉ុន្តែប្រាក់នោះនឹងមិនមែនជាក្រដាស់ប្រាក់ដូចគ្នានឹងអ្វីដែលអ្នកឲ្យខ្ចីបានប្រគល់ឲ្យឡើយ។

កិច្ចសន្យាខ្ចីបរិភោគត្រូវបានបែងចែកជាពីរប្រភេទគឺៈកិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់និងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់។កិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។ ក្នុងករណីដែលកិច្ចសន្យាដែលមិនយកការប្រាក់ត្រូវធ្វើឡើងដោយផ្ទាល់មាត់ ប្រសិនបើអ្នកឲ្យខ្ចីមិនទាន់ប្រគល់វត្ថុខ្ចីជាក់លាក់នៅឡើយទេអ្នកឲ្យខ្ចីអាចបញ្ឈប់ការឲ្យខ្ចីលុយនោះបាន ដោយមិនចាំបាច់មានមូលហេតុច្បាស់លាស់ទេ។កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់គឺជាកិច្ចសន្យាដែលតម្រូវឲ្យមានតម្លៃថ្នូរ។ ការប្រាក់អាចជាទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬវត្ថុដែលបានខ្ចី ( ប្រាក់ដើម) មកគុណជាមួយនឹងអត្រាការប្រាក់ដែលបានកំណត់ទៅតាមសមាមាត្រនឹងអំឡុងពេលដែលបានប្រើប្រាស់។ ដើម្បីធ្វើឲ្យការបង់ការប្រាក់ក្លាយជាសិទ្ធិលើបំណុលជាប្រយោជន៍អ្នកឲ្យខ្ចីការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនិងមានចុះហត្ថលេខាដោយអ្នកខ្ចី។មានន័យថាកិច្ចសន្យាខ្ចីដោយយកការប្រាក់ត្រូវធ្វើជាលាយលក្ខណ៍អក្សរជាដាច់ខាត។ គូភាគីអាចព្រមព្រៀងគ្នាកំណត់អត្រាការប្រាក់ដោយសេរី ប៉ុន្តែមិនអាចលើពីអត្រាការប្រាក់អតិបរមាដែលច្បាប់បានកំណត់ ឬ បទដ្ឋានគតិយុត្តផ្សេងឡើយ។ ប្រកាសចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ដែលត្រូវបានកំរិតកំណត់យកអត្រាការប្រាក់អតិបរមាត្រឹម ១៨% ក្នុងមួយឆ្នាំ។ ក្នុងករណីដែលគូភាគីបានត្រឹមកំណត់ថាយកការប្រាក់ប៉ុន្តែមិនបានកំណត់អត្រាការប្រាក់ជាក់លាក់នោះទេអត្រាការប្រាក់តាមច្បាប់ ៥% ក្នុង១ឆ្នាំ។ បើគ្មានការកំណត់ពិសេសទេ ការប្រាក់ត្រូវបង់នៅរៀងរាល់ពេលដែលពេលវេលា១ឆ្នាំបានកន្លងផុត គិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ។អ្នកឲ្យខ្ចីមានករណីយកិច្ចឲ្យអ្នកខ្ចីប្រើប្រាស់វត្ថុដោយសមស្របតាមកិច្ចសន្យា។ រីឯអ្នកខ្ចីអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុ ដោយសេរីបាន ហើយត្រូវទទួលបន្ទុកហានិភ័យ លើការ

បាត់បង់ ឬ ខូចខាតចំពោះវត្ថុដែលជាកម្មវត្ថុដែលកើតឡើងដោយសារមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឲ្យខ្ចីក្នុងនាមជាកម្មសិទ្ធិករគិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុ។ អ្នកខ្ចីមានករណីយកិច្ចត្រូវសងទៅឲ្យអ្នកខ្ចីនូវវត្ថុដែលមានប្រភេទ គុណភាពនិងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់នៅថ្ងៃដែលត្រូវសង។

ជាចុងក្រោយ ឆ្លងកាត់តាមរយៈខ្លឹមសារសារណានេះយើងខ្ញុំសង្ឃឹមថាបានចូលរួមចំណែកក្នុងការជួយជាយោបល់ ឬជាការប្រឹក្សាបានមួយផ្នែកតូចចំពោះអ្នកចង់សិក្សាក្នុងវិស័យច្បាប់ក៏ដូចជាប្រជាពលរដ្ឋសាមញ្ញដែលមានគោលបំណងខ្ចីក្នុងកិច្ចសន្យាខ្ចីបរិភោគ ដើម្បីការពារផលប្រយោជន៍របស់ភាគីនីមួយៗនិងលក្ខខណ្ឌដែលភាគីទាំងសងខាងត្រូវគោរពកុំឲ្យមានភាពថ្លោះធ្លោយដោយប្រការណាមួយដែលនាំឲ្យផ្ទុយច្បាប់នាំឲ្យកើតមានផលវិបាកក៏ដូចជាជម្លោះផ្សេងៗទៅថ្ងៃខាងមុខ។ ជាថ្មីម្តងទៀតថ្វីត្បិតតែសារណានេះមិនទាន់មានលក្ខណៈសុក្រឹត្យឲ្យបានមួយរយភាគរយក៏ពិតមែនតែខ្ញុំសង្ឃឹមយ៉ាងមុតមាំថាវានឹងជួយជាគំនិតមួយផ្នែកក្នុងការជួយពង្រឹងវិស័យយុត្តិធម៌ និងចូលរួមដោះស្រាយភាពអសកម្មទាំងឡាយដែលកើតមានក្នុងកិច្ចសន្យាខ្ចីបរិភោគបានមួយផ្នែកដែរ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការស្រាវជ្រាវនិងការតាក់តែងអត្ថបទសារណានេះក្រោមប្រធានបទមួយដែលមានចំណងជើងថា "**កិច្ចសន្យាខ្ចីបរិភោគ**" រួចមកយើងខ្ញុំមានមតិយោបល់មួយចំនួនដើម្បីធ្វើការរំលឹកនិងដាស់តឿនដល់អ្នកប្រតិបត្តិការក្នុងកិច្ចសន្យាខ្ចីបរិភោគដើម្បីឲ្យដំណើរកាន់តែមានសុវត្ថិភាពនិងរលូនទាំងអ្នកឲ្យខ្ចីនិងអ្នកខ្ចី។ចៀសវាងនិងកាត់បន្ថយនូវជម្លោះផ្សេងៗដែលនាំឲ្យមានបញ្ហា។

យើងដឹងហើយថាក្នុងជីវភាពរស់នៅប្រចាំថ្ងៃគេតែងតែសង្កេតឃើញការខ្ចីប្រាក់ភាគច្រើនធ្វើឡើងដោយផ្ទាល់មាត់ ព្រោះយល់ថាជាមនុស្សស្គាល់គ្នា។ ចំពោះច្បាប់ក៏មិនតម្រូវឲ្យគូភាគី ចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនោះទេមានន័យថាកិច្ចសន្យាអាចធ្វើឡើងដោយផ្ទាល់មាត់ឬមានលិខិតស្នាមក៏បាន។ ក៏ប៉ុន្តែក្នុងករណីមានវិវាទ ដោយភាគីណាមួយបំពាន ឬរំលោភ មិនអនុវត្តន៍កាតព្វកិច្ចនោះ គេពិតជាពិបាករកសំអាងហេតុផល ភស្តុតាងដើម្បីបញ្ជាក់ក្នុងការទាមទារនៅក្នុងសវនាការ។ដូច្នេះដើម្បីធានាឲ្យមានទំនុកចិត្តគូភាគីគួរតែធ្វើជាកិច្ចសន្យាមានទម្រង់ជាលាយលក្ខណ៍អក្សរ។ មួយវិញនៅក្នុងកិច្ចសន្យានោះត្រូវកំណត់ឲ្យច្បាស់អំពីកម្មវត្ថុនិងអត្រាការប្រាក់ដែលបានព្រមព្រៀងគ្នា។ ហើយអត្រាការប្រាក់នេះយល់ល្អគួរតែកុំឲ្យហួសនូវអតិបរមាដែលច្បាប់បានកំណត់។នេះជាចំណុចមួយដែលភាគច្រើនបងប្អូនប្រជាពលរដ្ឋមួយចំនួនមិនសូវដឹងអំពីអត្រាការប្រាក់ដែលច្បាប់បានកំណត់នោះទេ។ មួយវិញទៀតអត្រាការប្រាក់ដែលបង់លើសតាមផ្លូវច្បាប់គឺយកទៅកាត់ជាមួយនឹងប្រាក់ដើម ហេតុនេះហើយបានជាពេលខ្លះម្ចាស់បំណុលអាចក្លាយជាកូនបំណុលវិញក៏មានដែរ។

លើសពីនេះគូភាគីត្រូវមានភាពអត់ធ្មត់ខ្ពស់មុននឹងឈានទៅដល់តុលាការដើម្បីជៀសវាងការចំណាយច្រើនទាំងពេលវេលានិងថវិកា។ សម្រាប់កូនបំណុលឬអ្នកខ្ចីត្រូវបន្ទន់ឥរិយាបថក្នុងការសងត្រលប់ទៅម្ចាស់បំណុលវិញក្នុងចំនួនទឹកប្រាក់ណាមួយសមរម្យនៃសមត្ថភាពខ្លួន។ហាមដាច់ខាតការប្រើអាកប្បកិរិយាជំរុញឲ្យម្ចាស់បំណុលប្តឹង។

កិច្ចសន្យាបរិភោគគឺជារឿងរដ្ឋប្បវេណីសុទ្ធសាធភាគីទាំងសងខាងគួរតែចរចានិងនិយាយគ្នាឲ្យបានសមរម្យនៅពេលដែលមានបញ្ហាកើតមានឡើងជៀសវាងប្រើប្រាស់នូវអំពើហិង្សាទៅដោះស្រាយបញ្ហា។ពេលខ្លះឈានទៅដល់អំពើឃាតកម្មក៏មានដែរដែលប្រែក្លាយរឿងរដ្ឋប្បវេណីឲ្យទៅជារឿងព្រហ្មទណ្ឌវាគ្មានចំណេញដល់គូភាគីទេមានតែការខាតបង់តែប៉ុណ្ណោះ៕

# ឯកសារយោង

# ឯកសារយោង

## វិធានច្បាប់

- ✓ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
- ✓ ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០
- ✓ ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
- ✓ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឆ្នាំ ១៩៩៦
- ✓ ក្រឹត្យច្បាប់ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា

## ប្រកាស

- ✓ ប្រកាសស្តីពីអត្រាការប្រាក់ដែលបានកម្រិត ឆ្នាំ២០១១

## សៀវភៅមេរៀន

- ✓ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣ គន្ថីទី៥ ឆ្នាំ ២០១៣
- ✓ នីតិរដ្ឋប្បវេណី គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជាឧបត្ថម្ភដោយអង្គការ JICA សមិទ្ធិផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចាប់ពីឆ្នាំ២០១២-២០១៧
- ✓ នីតិកាតព្វកិច្ច របស់លោកសាស្ត្រាចារ្យ ញ៉ឹក វុធ្ធី បោះពុម្ពឆ្នាំ២០១៧
- ✓ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌ ២០១៦

## វចនានុក្រម

- ✓ វចនានុក្រម សម្តេចសង្ឃជួនណាត
- ✓ វចនានុក្រម Black's Law បោះពុម្ពលើកទី៧ ឆ្នាំ១៩៩៩

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ១២៨ កយធ.ប្រក/១១

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ [illegible] ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## អត្រាការប្រាក់ដែលត្រូវបានកម្រិត

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

## សម្រេច

**ប្រការ ១.-**

អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ (មួយ) ឆ្នាំ។

**ប្រការ ២.-**

អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវ

ផ្លូវសម្តេចសុធារស. ខណ្ឌដូនពេញ. ក្រុងភ្នំពេញ ទូរស័ព្ទ : 023 216 322 . 023 215 638

បានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។

<u>ប្រការ ៣</u>.-

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការ -អយ្យការអមតុលាការគ្រប់ជាន់ថ្នាក់
-ឯកសារ-កាលប្បវត្តិ។

កិច្ចសន្យាខ្ចីបរិភោគ

អ្នកកាត់តែងលិខិត..........................

លេខ:.......................................

ក្រដាសពុម្ពលេខ:..................

ទីទុកឯកសារ

# <u>កិច្ចសន្យាខ្ចីបរិភោគ</u>

## ១. ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

១. កូនបំណុលឈ្មោះ: .......................ភេទ............ថ្ងៃខែឆ្នាំកំណើត:.................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:...............................ចុះថ្ងៃទី................មានអាសយដ្ឋានផ្ទះលេខ:... ផ្លូវលេខ:...........ភូមិ...........សង្កាត់.....................ខណ្ឌ.................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

អ្នកធានាដោយវត្ថុឈ្មោះ:...............................ភេទ........ថ្ងៃខែឆ្នាំកំណើត:...................... សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:...............................ចុះថ្ងៃទី...............................និង ឈ្មោះ:...........................ភេទ.......ថ្ងៃខែឆ្នាំកំណើត:.......................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:...........................ចុះថ្ងៃទី...........................មានលំនៅផ្ទះលេខ:.......... ផ្លូវលេខ:..........ភូមិ...........សង្កាត់....................ខណ្ឌ.......................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

២. ម្ចាស់បំណុលឈ្មោះ:............................ភេទ.......ថ្ងៃខែឆ្នាំកំណើត:................សញ្ជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ:.........................ចុះថ្ងៃទី...............មានលំនៅផ្ទះលេខ:........ភូមិ... សង្កាត់.................ខណ្ឌ..................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ខ") ។

## ២. សិទ្ធលើបំណុលដែលត្រូវធានាដោយសិទ្ធិលើការបញ្ចាំ

កូនបំណុលឈ្មោះ:.........................ភេទ.........ថ្ងៃខែឆ្នាំកំណើត:...................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:.........................ចុះថ្ងៃទី.......................និងលោកស្រី.............. ភេទ..........ថ្ងៃខែឆ្នាំកំណើត:...........................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:................ ចុះថ្ងៃទី...........................មានលំនៅផ្ទះលេខ:.........ផ្លូវលេខ:........សង្កាត់............ខណ្ឌ............ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

(១). ចំនួនប្រាក់ដើម..........................................

(២). អំឡុងពេល..........................................

(៣). ការប្រាក់..........................................

(៤). ប្រាក់ធានាសង..........................................

(៥). ការសន្យាពិសេសកិច្ចសន្យានេះធ្វើឡើង សម្រាប់រយៈពេល..........ឆ្នាំ ប៉ុន្តែកិច្ចសន្យានេះអាចបញ្ចប់ ឬរំលាយមុនរយៈពេលនេះបាន ក្នុងករណីភាគីណាមួយបំពានចំណុចណាមួយ នៃបញ្ញត្តិស្តីពីការបំពានលើកាតព្វកិច្ចដូចមានចែងនៅក្នុង **"ឧបសម្ព័ន្ធ(ក) និង(ខ) នៃកិច្ចសន្យានេះ"** ។

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាឱបរិភោគដែលមានចែងនៅក្នុងចំណុច២ខាងលើ ។

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងគ្នាបង្កើតសិទ្ធិលើការបញ្ចាំ **ធានា** លើសិទ្ធិនៃចំណុច៣ដើម្បីធានាសិទ្ធិលើបំណុលដែលមានចែងនៅចំណុចទី២ ខាងលើ និងប្រគល់កម្មវត្ថុអោយទៅភាគី -ខ- ។

**៣. អត្តសញ្ញាណអចលនវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ**

(១). ទីតាំងដីស្ថិតនៅ: ដីឡូតិ៍លេខ:.......... ផ្លូវលេខ:.......... ភូមិ.......... សង្កាត់..........
ខណ្ឌ.................. រាជធានីភ្នំពេញ ។

(២). លេខក្បាលដី..............................

(៣). លេខប័ណ្ណ:..................................................

**៤. ខសន្យាផ្សេងៗទៀត**

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងគ្នាកំណត់អំពីលក្ខខណ្ឌផ្សេងៗទៀតដូចមានចែងនៅក្នុង**ឧបសម្ព័ន្ធ (ក)** នៃកិច្ចសន្យានេះ ។

ធ្វើជា........ច្បាប់ នៅថ្ងៃទី.......... ខែ.............. ឆ្នាំ២០១៦

**បានអានសេចក្ដីនៃលិខិតនេះអោយគូភាគីស្ដាប់ចំពោះមុខសាក្សី**

ឈ្មោះ:.................................... អាយុ.............. ឆ្នាំ ទីលំនៅសង្កាត់................ ខណ្ឌ........ រាជធានីភ្នំពេញ ។

ឈ្មោះ:.................................... អាយុ.............. ឆ្នាំ ទីលំនៅសង្កាត់................ ខណ្ឌ........ រាជធានីភ្នំពេញ ។

| | | |
|---|---|---|
| **ស្នាមមេដៃ** | **ស្នាមមេដៃ** | **បានឃើញ និងបញ្ជាក់ថា** |
| ភាគី -ក- | ភាគី -ខ- | គូភាគីបានផ្ដិតមេដៃចំពោះមុខមេធាវីជាសាក្សី |